គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

Cooperation Committee for Cambodia

Comité de Coopération Pour le Cambodge


របាយការណ៍ស្ទង់មតិ

# សកម្មភាព និងផលប៉ះពាល់ របស់អង្គការសង្គមស៊ីវិល ពីជំងឺរាតត្បាត កូវីដ១៩

ខែមេសា ឆ្នាំ២០២០

# របាយការណ៍ស្ទង់មតិ

# សកម្មភាព និងផលប៉ះពាល់របស់អង្គការសង្គមស៊ីវិល

# ពីជំងឺរាតត្បាត "កូវីដ១៩"

ខែមេសា ឆ្នាំ២០២០

# មាតិកា


ពាក្យកាត់ .......... 3
សេចក្តីថ្លែងអំណរគុណ .......... 4
បុព្វកថា .......... 5
ខ្លឹមសារសង្ខេប .......... 6

**១. សេចក្តីផ្តើម** .......... 8
**២. គោលបំណងនៃការស្រាវជ្រាវ** .......... 8
**៣. វិធីសាស្ត្រស្រាវជ្រាវ** .......... 9
**៤. លទ្ធផលសំខាន់ៗពីការស្ទង់មតិ** .......... 10
**៤.១. សារតារបស់អ្នកឆ្លើយតប** .......... 10
៤.១.១. ប្រភេទអង្គការ និងឋានានុក្រមរបស់អ្នកឆ្លើយតប .......... 10
៤.១.២. ប្រភេទអ្នកទទួលផល .......... 11
៤.១.៣. តាមវិស័យការងារ .......... 12
៤.១.៤. តំបន់គោលដៅនៃកម្មវិធី .......... 12
**៤.២. សកម្មភាព និងផលប៉ះពាល់កម្រិតសកម្មភាព និងកម្មវិធី** .......... 13
៤.២.១. កម្រិតនៃផលប៉ះពាល់លើកម្មវិធី និងសកម្មភាព .......... 13
៤.២.២. បញ្ហាប្រឈមលើកម្មវិធី និងកម្រិតសកម្មភាព .......... 14
៤.២.៣. សកម្មភាពឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាជំនួយទៅកាន់អ្នកទទួលផល .......... 16
**៤.៣. សកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន** .......... 17
៤.៣.១. បញ្ហាប្រឈមមុខនៃកម្រិតស្ថាប័ន .......... 17
៤.៣.២. សកម្មភាពអង្គការ និងការពិចារណាយ៉ាងហ្មត់ចត់ ដើម្បីឆ្លើយតបជំងឺកូវីដ១៩ .......... 18
៤.៣.៣.សកម្មភាពឆ្លើយតប ប្រសិនបើការឆ្លងនៅតែបន្តរហូតដល់រយៈពេលខែ ឬយូរជាងនេះ.19
៤.៣.៤. គណនេយ្យភាពសម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងអ្នកទទួលផល ប្រសិនបើបន្តការឆ្លង 22
**៥. សំណូមពរ និងយោបល់ផ្សេងៗ** .......... 25
**៥.១. សម្រាប់ អង្គការ គ.ស.ក** .......... 25
**៥.២. សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ** .......... 28
**៥.៣. សម្រាប់រាជរដ្ឋាភិបាល** .......... 29

ឧបសម្ព័ន្ធ១: កម្រងសំណួរសម្រាប់ស្ទង់មតិ .......... 31

## ពាក្យកាត់

| | |
|---|---|
| ស៊ី.ប៊ី.អូ (CBOs) | អង្គការសហគមន៍មូលដ្ឋាន |
| ស៊ី.ស៊ី.ស៊ី (CCC) | អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) |
| ស៊ី.ឌី.ស៊ី (CDC) | មជ្ឈមណ្ឌលសម្រាប់គ្រប់គ្រង និងការពារជំងឺឆ្លង |
| ស៊ី.អ៊ឹម.ឌី (CMD) | ទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាព |
| ស៊ី.អេស.អូ (CSOs) | អង្គការសង្គមស៊ីវិល |
| កូវីដ១៩ (COVID-19) | វីរុសឆ្លងកូរ៉ូណា (កូវីដ១៩) |
| ឌី.អ័រ.អ័រ (DRR) | ការកាត់បន្ថយគ្រោះមហន្តរាយ និងហានិភ័យ |
| អែហ្វ.អេន.ជី.អូ (FNGOs) | អង្គការមិនមែនរដ្ឋាភិបាលបរទេស |
| ជី.ឌី.ធី (GDT) | អគ្គនាយកដ្ឋានពន្ធដារ |
| អាយ.អ៊ី.ស៊ី (IEC) | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| អេល.អិន.ជី.អូ (LNGOs) | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| អឹម.អែហ្វ.អាយ (MFI) | វិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ |
| អឹម.អូ.អេច្ឆ (MoH) | ក្រសួងសុខាភិបាល |
| អិន/អេ (N/A) | មិនមានចម្លើយ |
| អិន.អ័រ.អឹម (NRM) | ការគ្រប់គ្រងធនធានធម្មជាតិ |
| អិន.អេស.អេស.អេហ្វ | មូលនិធិជាតិ សន្តិសុខសង្គម |
| ដាប់ប៊ិលយូ.អេច្ឆ.អូ (WHO) | អង្គការសុខភាពពិភពលោក |

# សេចក្តីថ្លែងអំណរគុណ


អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បី កម្ពុជា (គ.ស.ក) តាមរយៈផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាព (ស៊ី.អឹម.ឌី) ដែលជាអ្នកសម្របសម្រួលលើកិច្ចការយ៉ាងជិតស្និតជាមួយនឹងសហការីផ្សេងទៀតក្នុងស្ថាប័ន សូមសម្តែងនូវសេចក្តីអំណរគុណ ដោយស្មោះត្រង់ទៅកាន់ ទាំងសមាជិក និងមិនសមាជិក របស់ អង្គការ គ.ស.ក បណ្តាញអង្គការតាមបណ្តាខេត្ត អង្គការសហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធនៃអង្គការសង្គមស៊ីវិលទាំងអស់ សម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃដើម្បីចូលរួមបំពេញក្នុងទម្រង់សំណួរស្ទង់មតិនេះ។ អរគុណផងដែរចំពោះប្រធានគ្រប់គ្រង និងបុគ្គលិក តាមផ្នែកនីមួយៗរបស់ អង្គការ គ.ស.ក សម្រាប់ការផ្តល់ធាតុចូល ក៏ដូចជា ការប្រមូលនូវទិន្នន័យពីអង្គការដៃគូ។ ជាងនេះ សូមអំណរគុណជាខ្លាំង ចំពោះលោក សឿង សារឿន ជានាយកប្រតិបត្តិនៃអង្គការ គ.ស.ក ដែលជាអ្នកផ្តួចផ្តើមគំនិតលើការស្ទង់មតិ ជាមួយនឹងការផ្តល់ប្រឹក្សាយោបល់ដ៏មានតម្លៃ ទៅលើមាតិកានៃការសិក្សា ក៏ដូចជានៅក្នុងរបាយការណ៍នេះ។ សូមអរគុណចំពោះលោក ជេន សុជឿន នៅក្នុងការរៀបចំរបាយការណ៍ ហើយក៏អរគុណផងដែរចំពោះ អ្នកស្រី លុយ ធារី ក្នុងការគាំទ្រសម្រាប់ការចងក្រងបផ្តុំនៃការវិភាគលើទម្រង់សំណួរបើកមួយចំនួន ក៏ដូចជាពិនិត្យឡើងវិញលើកម្រងសំណួរទាំងនេះ ហើយក៏ពេញចិត្តជាការខ្លាំងសម្រាប់ការផ្តល់មតិយោបល់ពីមិត្តរួមការងារ និងសមាជិករបស់យើងទាំងអស់ទៅលើលទ្ធផលបឋម។

ជាចុងក្រោយ សូមថ្លែងអរគុណដល់អ្នកចូលរួមក្នុងការស្ទង់មតិនេះ ហើយយើងរំពឹងថា របាយការណ៍នេះ នឹងក្លាយទៅជាឯកសារគន្លឹះ សម្រាប់សមាជិក និងដៃគូដទៃទៀតរបស់ អង្គការ គ.ស.ក ដើម្បីងាយស្រួល និងបានជ្រួតជ្រាបពីស្ថានភាពនាពេលថ្មីៗនេះ ពីផលប៉ះពាល់របស់ជំងឺកូវីដ១៩ ទៅលើកម្មវិធី អង្គការ និងការឆ្លើយតបក៏ដូចជាត្រៀមរបស់សង្គមស៊ីវិលពាក់ព័ន្ធ។

*អរគុណលោក យ៉ងយ៉ាង ចន្ទ្រសីហា សម្រាប់ការសម្រួលរបាយការណ៍ជាភាសាខ្មែរ*

## បុព្វកថា

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាព បានផ្តួចផ្តើមសម្រង់ស្ទង់មតិនេះឡើង ក្នុងគោលបំណងស្វែងយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើអង្គការសង្គមស៊ីវិល ក៏ដូចជាស្វះស្វែងរកសំណូមពរឆ្លើយតបទៅនឹងពីផលប៉ះពាល់ផ្សេងៗ នាពេលថ្មីៗនេះ សម្រាប់កម្មវិធី និងស្ថាប័ន អង្គការសង្គមស៊ីវិល និងក្រុមអ្នកទទួលផល។ ការសម្រង់ស្ទង់មតិឆាប់នេះត្រូវបានប្រមូលជាទិន្នន័យកំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩ នៅចុងខែមីនារហូតដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ដើម្បីវាយតម្លៃផលប៉ះពាល់ និងទទួលធាតុចូល ពីភាគីពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទងជាមួយនឹងអង្គការសង្គមស៊ីវិល។ លទ្ធផលចេញពីការសិក្សានេះឆ្លុះបញ្ចាំងពីស្ថានភាព និងសកម្មភាពកម្រិតកម្មវិធី ក៏ដូចជាស្ថាប័ន។ លើសពីនេះទៅទៀត សំណូមពរ និងការផ្តល់មតិយោបល់ផ្សេងៗ ត្រូវដាក់រួមបញ្ចូលគ្នា ក្នុងការចូលរួមដោះស្រាយ ឬលើកឡើងពីបញ្ហាប្រឈមទៅកាន់ភាគីពាក់ព័ន្ធផ្សេងៗ ដែលមានជាពិសេសទៅកាន់អង្គការ គ.ស.ក ដៃគូអភិវឌ្ឍន៍/ដៃគូមូលនិធិ និងរាជរដ្ឋាភិបាល។

លទ្ធផលនេះគឺពិតជាមានអត្ថប្រយោជន៍ ក្នុងការផ្តល់ព័ត៌មានទៅកាន់រាល់ភាគីពាក់ព័ន្ធនូវអ្វីដែលអង្គការសង្គមស៊ីវិលកំពុងតែធ្វើ និងកំពុងពិចារណា ក៏ដូចជាការលើកឡើងនូវការផ្តល់យោបល់ផ្សេងៗ ក្នុងការឆ្លើយតបទៅការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ ដែលបានសាយភាយពាសពេញពិភពលោក។ យើងខ្ញុំសង្ឃឹមថា លទ្ធផលនេះ អាចផ្តល់ដល់យើងទាំងអស់គ្នា នូវអ្វីដែលយើងបានចូលរួមធ្វើក្នុងការដោះស្រាយ ក៏ដូចជាអ្វីដែលយើងទាំងអស់គ្នា គួរខិតខំបន្តទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលថ្មីៗនេះ និងយុទ្ធសាស្ត្រដោះស្រាយសម្រាប់ពេលអនាគត។

**សឿង សារឿន**

នាយកប្រតិបត្តិ នៃអង្គការ គ.ស.ក

ខែមេសា ឆ្នាំ២០២០

## ខ្លឹមសារសង្ខេប

ការស្ទង់មតិនេះត្រូវបានធ្វើឡើងដោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា (គ.ស.ក) ក្នុងកំឡុងពេលការរីកសាយភាយនៃជំងឺកូវីដ១៩ នៅទូទាំងពិភពលោកក៏ដូចជា ក្នុងប្រទេសកម្ពុជាផងដែរ ក្នុងគោលបំណងដើម្បីស្វែងយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើកម្មវិធីសកម្មភាពរបស់អង្គការសង្គមស៊ីវិល ក៏ដូចជាស្វែងរកសំណូមពរឆ្លើយតប លើផលប៉ះពាល់នាពេលថ្មីៗនេះ។ ទម្រង់ស្ទង់មតិនេះត្រូវបានចែកចាយទៅកាន់សមាជិករបស់អង្គការ គ.ស.ក រួមទាំងបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលតាមបណ្ដាខេត្ត អង្គការសហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធដទៃទៀត ដែលបានកំពុងធ្វើការទាក់ទងជាមួយនឹងអង្គការសង្គមស៊ីវិល។ ជាលទ្ធផល មានអ្នកឆ្លើយតបចំនួន ១៥៤ ដែលកំពុងធ្វើការលើវិស័យចម្រុះផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា។

ជាលទ្ធផលនៃស្ទង់មតិនេះ បានចង្អុលបង្ហាញពីផលប៉ះពាល់យ៉ាងច្រើន លើការងារ និងគម្រោងកម្មវិធី ព្រមទាំងអង្គការ ដែលអាចប្រៀបធៀបមានលក្ខណៈស្រដៀងគ្នា។ សម្រាប់កម្មវិធី ស្ទើរជិតពាក់កណ្ដាលនៃអ្នកឆ្លើយតប បានធ្វើចំណាត់ថ្នាក់ក្នុងចំណោមផលប៉ះពាល់អាក្រក់ក្នុងកម្រិតខ្ពស់ ៤៧ ភាគរយ/៧២នៃអ្នកឆ្លើយតប ពីជំងឺកូវីដ១៩ ខណៈដែលក្នុងកម្រិតស្ថាប័នក៏មានផលប៉ះពាល់អាក្រក់ យ៉ាងតិចបំផុត ៤៦ភាគរយ ដែលស្ថិតក្នុងកម្រិត មិនអាចធ្វើសកម្មភាពភាគច្រើនដូចការគ្រោងទុក។ មានគម្រូរមួយចំនួន នៃបញ្ហាប្រឈម គឺពាក់ព័ន្ធការពន្យាពេលនៃគម្រោងសកម្មភាព បញ្ហាប្រឈមរបស់បុគ្គលិក បញ្ហាកញ្ចប់ថវិកា/មូលនិធិ សម្ភារៈគាំទ្រពីការឆ្លើយតបបន្ទាន់ សម្ភារៈដើម្បីបម្រើកិច្ចការតាមប្រព័ន្ធអនឡាញ បញ្ហាបណ្ដាញប្រព័ន្ធអ៊ីធឺណែត ការខ្វះខាតព័ត៌មាន ការរឹតត្បឹតនៃការជួបជុំក្រុម/ការជួបប្រជុំ និងបញ្ហាផ្សេងៗទៀត។

ក្នុងការឆ្លើយតបទៅនឹងការរាតត្បាត ការដាក់ចេញនូវសកម្មភាពឆ្លើយតបមួយចំនួនត្រូវបានធ្វើឡើង និងគិតណាយ៉ាងយកចិត្តទុកដាក់ ដើម្បីអនុវត្ត ក្នុងចំណោមរាល់ប្រភេទចម្លើយពាក់ព័ន្ធផ្សេងៗគ្នារួមមាន៖ ជាមួយនឹងបុគ្គលិក ម្ចាស់ជំនួយ អ្នកទទួលផល និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្នុងចំណោមទាំងនោះមាន ៩៤% ទើបបានលើកកម្ពស់សុខមាលភាព និងការអនុវត្ត ដែលមានសុវត្ថិភាពសម្រាប់បុគ្គលិក។ ជាមួយអត្រាចំនួន ៨៨% បានរក្សាទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ អំពីការកែប្រែផែនការសកម្មភាព និងមាន ៨៧% ដែលអនុញ្ញាតឱ្យបុគ្គលិកមានភាពបត់បែនទៅនឹងការរៀបចំការងាររបស់ខ្លួន (ឧទាហរណ៍៖ ធ្វើការពីផ្ទះ/ចម្ងាយ) និងការឆ្លើយតបសកម្មភាពជាច្រើនទៀតដើម្បីជួយអ្នកទទួលផលនៃកម្រិតកម្មវិធី។

បន្ថែមពីនេះទៅទៀត មានការបើកចំហានូវការផ្តល់យោបល់ និងសំណូមពរទៅកាន់ភាគីពាក់ព័ន្ធសំខាន់ផ្សេងៗ ទាំងនោះរួមមាន៖ ១) ចំពោះអង្គការ គ.ស.ក៖ ការចែករំលែកព័ត៌មាន ការគៀរគរធនធាន និងជំនួយឧបត្ថម្ភផ្សេងៗ ការជួយជាសម្ភារៈអនាម័យ និងសម្ភារៈសម្រាប់ការអប់រំផ្សព្វផ្សាយផ្សេងៗ ការសិក្សារៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព ការអនុវត្តច្បាប់និងពន្ធដារ ការសិក្សាស្រាវជ្រាវ និងការវាយតម្លៃផលប៉ះពាល់ យន្តការការងារជាមួយនឹងភាគីពាក់ព័ន្ធកំឡុងពេល និងក្រោយនៃជំងឺកូវីដ១៩ ការកសាងបណ្តាញ និងកិច្ចសហការ ។ល។ ២) ចំពោះម្ចាស់ជំនួយ៖ ការប្រឹក្សាពិគ្រោះយោបល់ជាមួយម្ចាស់ជំនួយ ដើម្បីស្វែងរកជម្រើស/ដំណោះស្រាយទៅលើរបៀបអនុវត្តគម្រោង និងជួយគាំទ្រក្រុមគោលដៅ ជួយបង្កើនការគាំទ្រហិរញ្ញវត្ថុចំពោះប្រតិបត្តិការគម្រោង និងសហគមន៍ រក្សាការគាំពារអត្ថប្រយោជន៍បុគ្គលិកនៅក្នុងរយៈពេលនៃការរាតត្បាតនេះ ផ្តល់នូវជំនួយមូលនិធិទៅលើការសង្គ្រោះបន្ទាន់ អនុញ្ញាតឱ្យមានការពន្យារិសាលភាពគម្រោង និងការជួយកែសម្រួលនៃអន្តរាគមន៍។ល។ ៣) ចំពោះរដ្ឋាភិបាល៖ ផ្តល់ជូននូវសកម្មភាពដ៏សមរម្យ និងគោលការណ៍ណែនាំច្បាស់លាស់ ផ្តល់នូវការជួយឧបត្ថម្ភចំណីអាហារទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ និងរងផលប៉ះពាល់ ជាពិសេសនោះអ្នកដែលនៅក្នុងតំបន់ដាច់ស្រយាល បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ធ្វើបច្ចុប្បន្នភាព និងចែករំលែកព័ត៌មានដែលគួរជឿទុកចិត្ត និងមានតម្លាភាពអំពីជំងឺកូវីដ១៩ ហើយនិងផលប៉ះពាល់របស់វា នៅក្នុងប្រទេសកម្ពុជា ជាដើម។

## ១. សេចក្តីផ្តើម

មកដល់ដើមឆ្នាំ២០២០ កិច្ចការងាររបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ទទួលរងនូវផលប៉ះពាល់ដោយសារវីរ៉ុសកូរូណា ឬជំងឺកូវីដ១៩ ដែលរីកសាយភាយយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក។ គិតមកដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ នៅក្នុងប្រទេសកម្ពុជា មានករណីឆ្លងជំងឺកូវីដ១៩ ចំនួន១២២ នាក់ ហើយនេះបង្កឱ្យមានក្តីព្រួយបារម្ភយ៉ាងខ្លាំង និងគួរឱ្យកត់សម្គាល់ក្នុងចំណោមសាធារណៈជន បើទោះបីចំនួនអ្នកជំងឺប្រហែលពាក់កណ្តាលទើបតែបានជាសះស្បើយពីការសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យក្តី។ ខណៈពេលឆ្លើយតបទៅនឹងវិធានការនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជា ឬសេចក្តីណែនាំមួយចំនួន ដើម្បីការពារពីការរីករាលដាលឆ្លងនៃជំងឺនេះនៅទូទាំងប្រទេស។ វិធានការទាំងនោះរួមមាន ការបិទសាលារៀន បិទការជួបជុំនៅទីកន្លែងសាធារណៈ ទីកន្លែងកំសាន្ត ការគ្រប់គ្រងពលករអន្តោប្រវេសន៍/ពលករចំណាកស្រុក ការប្រារព្ធកម្មវិធីសង្គម និងពិធីបុណ្យសាសនា ក៏ដូចជាលទ្ធភាពនៃការដាក់ប្រទេសនៅក្នុងភាពមានអាសន្ន ដូចដែលសេចក្តីព្រាងច្បាប់ទើបតែបានពិភាក្សារួចរាល់។ បញ្ហានេះតិច ឬច្រើនបានធ្វើឱ្យមានផលប៉ះពាល់ចំពោះ សកម្មភាព និងលទ្ធផលរបស់អង្គការសង្គមស៊ីវិលសម្រាប់ការអនុវត្តកម្មវិធី និងដំណើរការអង្គការ។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដែលជាអង្គការសមាជិកភាពដែលមានអាយុកាលវ័យចំណាស់ជាងគេមួយនេះ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការងារសម្របសម្រួល អភិបាលកិច្ច និងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ហើយបានផ្តួចផ្តើមការស្ទង់មតិនេះឡើង។ ក្នុងរបាយការណ៍នេះនឹងបង្ហាញជាពិសេសពីប្រវត្តិព័ត៌មានរបស់អ្នកផ្តល់ចម្លើយ សកម្មភាព និងផលប៉ះពាល់នូវកម្រិតកម្មវិធី និងកម្រិតស្ថាប័នទាំងរយៈពេលខ្លី ក៏ដូចជាវែង ព្រមទាំងផ្នែកចុងក្រោយ មានសំណើផ្សេងៗ សម្រាប់ដៃគូពាក់ព័ន្ធសំខាន់ៗ។ តាមការរំពឹងទុក លទ្ធផលនេះនឹងជាការជូនដំណឹងដ៏ល្អមួយ សម្រាប់អង្គការសង្គម ស៊ីវិល និងរាល់ដៃគូក្នុងការរៀបចំយុទ្ធសាស្ត្រ និងសកម្មភាពក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមថ្មីៗ និងដំណោះស្រាយផ្សេងៗជាមួយបញ្ហាទាំងនេះ។

## ២. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីស្វែងយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើការអនុវត្តការងាររបស់អង្គការសង្គមស៊ីវិលពីជំងឺកូវីដ១៩ ទៅលើកម្មវិធី ស្ថាប័ន និងក្រុមគោលដៅក៏ដូចជាស្វែងរកនូវមតិយោបល់ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមថ្មីៗ និងយុទ្ធសាស្ត្ររយៈពេលវែង។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅក្នុងភាពបន្ទាន់របស់អង្គការសង្គមស៊ីវិលកំឡុងពេលនៃការវាយប្រហារដោយជំងឺឆ្លងកូវីដ១៩។ កម្រងសំណួរត្រូវបានគ្រោងឡើងទាំងតាមសារអេឡិចត្រូនិច និងទម្រង់បំពេញអនឡាញ តាមរយៈទម្រង់ហ្គូហ្គល និងផ្ញើទៅកាន់ប្រព័ន្ធទំនាក់ទំនងដែលមានពីអង្គការ គ.ស.ក ដល់អ្នកដែលកំពុងធ្វើការទាក់ទងទៅនឹងការងារអង្គការសង្គមស៊ីវិល។ អ្នកទាំងនោះរួមមានសមាជិក និងមិនទាំងសមាជិករបស់ អង្គការ គ.ស.ក បណ្តាញអង្គការសង្គមស៊ីវិលតាមបណ្តាខេត្ត អង្គការសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត។ ក្រៅពីប្រព័ន្ធអេឡិចត្រូនិចអ៊ីម៉ែល តំណភ្ជាប់នៃការស្ទង់មតិនេះ ក៏ត្រូវបានផ្សព្វផ្សាយចែករំលែកទៅក្នុងគេហទំព័រហ្វេសប៊ុករបស់ អង្គការ គ.ស.ក ក៏ដូចជាប្រព័ន្ធសង្គមចែកចាយដទៃទៀតដូចជា ក្រុមតេឡេក្រាម ព្រមទាំងលើកទឹកចិត្តឱ្យដៃគូផ្សេងទៀត ក្នុងការចែករំលែកបន្តនៃសម្រង់ស្ទង់មតិនេះ ហើយមានការរំលឹកឡើងវិញតាមសារអេឡិចត្រូនិចក្នុងការជម្រុញលើកទឹកចិត្តអោយមានការចូលរួមផ្តល់ចម្លើយរហូតដល់កាលបរិច្ឆេទបិទ។

ការប្រមូលទិន្នន័យគឺត្រូវបានបង្កើតឡើងកាលពីចុងខែមីនា រហូតដល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២០ ហើយជាលទ្ធផលមានការឆ្លើយតបចំនួន ១៥៩ ក្នុងការស្ទង់មតិនេះ។ ក្នុងចំណោមការឆ្លើយតបទាំងនោះមាន ១៩អង្គការ ដែលមានលើសពីមួយនាក់ចូលរួមនៅក្នុងការឆ្លើយតប។ សម្រាប់សម្រង់ស្ទង់មតិនេះ មានសំណួរមួយចំនួនត្រូវបានធ្វើឡើង ជាប្រភេទចម្លើយបើក ដើម្បីទទួលបាននូវការឆ្លើយតបចម្រុះផ្សេងៗគ្នា *(សូមមើលកម្រងសំណួរស្ទង់មតិនៅក្នុងឧបសម្ព័ន្ធ)*។ ជាចុងក្រោយ ទិន្នន័យដែលទទួលបាននេះត្រូវបានយកមកវិភាគ ជាមួយនឹងស្ថិតិបរិយាយរៀបរាប់ (descriptive statistic) និងតម្រៀបកូដចម្លើយបើកទាំងនោះតាមប្រភេទ ព្រមទាំងធ្វើការវាស់វែងនូវចំនួនចម្លើយទាំងនោះតាមបែបបរិមាណ ដើម្បីវាយតម្លៃពីទំហំ ថាតើការឆ្លើយតបណាខ្លះ ដែលមានចំនួនតិច និងច្រើន។ ម្យ៉ាងវិញទៀតរាល់ការចូលរួមជាមតិយោបល់ និងសំណូមពរ ក៏ត្រូវបានចងក្រងជារួមនៅផ្នែកចុងក្រោយទៅក្នុងរបាយការណ៍នេះផងដែរ។

# ៤. លទ្ធផលសំខាន់ៗពីការស្ទង់មតិ

## ៤.១. សាវតារបស់អ្នកឆ្លើយតប

### ៤.១.១. ប្រភេទអង្គការ និងឋានានុក្រមរបស់អ្នកឆ្លើយតប

ប្រវត្តិសាវតារបស់អ្នកឆ្លើយតបត្រូវបានពិភាក្សានៅក្នុងរបាយការណ៍នេះ ផ្តោតទៅលើប្រភេទអង្គការ ឋានានុក្រម (តួនាទី) របស់អ្នកឆ្លើយតប ប្រភេទអ្នកទទួលផលផ្ទាល់ ដែលអង្គការកំពុងធ្វើការ និងតំបន់គោលដៅ ដែលកម្មវិធីកំពុងដំណើរការ។

តាមរយៈសម្រង់ស្ទង់មតិមានការចូលរួមពីអ្នកឆ្លើយតបចំនួន ១៥៤ ដែលក្នុងចំណោមអ្នកទាំងនោះមានអង្គការចំនួន១៤ ដែលមានអ្នកឆ្លើយតបផ្សេងគ្នាក្នុងមួយអង្គការ ដោយសារតែការទទួលបាននូវការចែករំលែកទម្រង់នៃការស្ទង់មតិផ្សេងៗគ្នា។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ មានច្រើនតំណាងអោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក រហូតដល់ ៦២ភាគរយ ខណៈដែល តំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេស ៣៤ ភាគរយ តំណាងអង្គការសហគមន៍មូលដ្ឋាន ៣ ភាគរយ និងមានតែ១ភាគរយប៉ុណ្ណោះ មកពីផ្នែកសិក្សាឬសាកលវិទ្យាល័យ និងអ្នកជំនាញ (freelance consultant) ដែលធ្វើការទាក់ទងនឹងកិច្ចការរបស់អង្គការសង្គមស៊ីវិល។

*រូប ៤.១ ប្រភេទអង្គការ និង រូប ៤.២. តួនាទីរបស់អ្នកឆ្លើយតប*



ម្យ៉ាងវិញទៀត អ្នកឆ្លើយតបដែលមានមុខតំណែងជាថ្នាក់ដឹកនាំ ឬប្រធានអង្គការ (៧៣%) ដែលមានអត្រាភាគរយខ្ពស់ក្នុងចំណោមនៃអ្នកឆ្លើយតបទាំងអស់ និងបន្ទាប់មកទៀត អ្នកធ្វើការជាអ្នកកម្មវិធី (១៥%) និងមានតែ ៦% ប៉ុណ្ណោះ ដែលជាបុគ្គលិកផ្នែកប្រតិបត្តិ។ លទ្ធផលនេះគឺជាការផ្តល់នូវទឡ្ហីករណ៍គន្លឹះមួយអំពីទិន្នន័យពាក់ព័ន្ធ ដែលគួរឱ្យជឿទុកចិត្ត សម្រាប់តំណាងជាលក្ខណៈអង្គភាពក្នុងការឆ្លុះបញ្ចាំងតាមស្ថាប័ននីមួយៗ ដែលលើកឡើងនៅក្នុងការស្ទង់មតិនេះ។

### ៤.១.២. ប្រភេទអ្នកទទួលផល

មានប្រភេទផ្សេងៗគ្នានៃអ្នកទទួលផលក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ ដែលស្ថិតក្នុងប្រភេទនៃក្រុមសង្គមផ្សេងៗគ្នាដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រុមអង្គការសហគមន៍មូលដ្ឋាន ក្រុមយុវជន ក្រុមដែលមានវ័យចំណាស់ ក្រុមស្ត្រី អ្នកក្រីក្រ សិស្ស/និស្សិត និងគ្រូបង្រៀនជាដើម។ ក្នុងនោះយុវជនមាន (១០២) និងកុមារ(៩៥) គឺមានចំនួនប្រហែកង់ច្រើនជាងគេ នៅក្នុងចំណោមក្រុមអ្នកទទួលផល។ ហើយបន្តបន្ទាប់មានក្រុមជនពិការភាព (៤៦) និង មនុស្សចាស់ (១២)។ ចំណែកឯប្រភេទក្រុមអ្នកទទួលផលដទៃទៀតគឺស្ថិតក្នុងទំហំតូច រាយប៉ាយក្នុងរង្វង់នៃទិន្នន័យនេះ។

*រូប ៤.៣. ប្រភេទនៃអ្នកទទួលផល*



### ៤.១.៣. តាមវិស័យការងារ

យ៉ាងហោចណាស់មានចំនួន ៣៥ វិស័យការងារត្រូវបានបែងចែកចេញពីចម្លើយនៃសំណួរបើកនេះ។ លទ្ធផល បង្ហាញឱ្យឃើញពីអង្គការរបស់អ្នកឆ្លើយតប ដែលកំពុងធ្វើការលើវិស័យផ្សេងៗគ្នា ហើយប្រេកង់នៃវិស័យចម្បងនោះគឺ វិស័យអប់រំ (៥៣) និងសុខភាព (៣៦) បន្ទាប់មកទៀតផ្តោតលើ អាហារូបត្ថម្ភ និងអនាម័យ (២៦) កសិកម្ម (២០) ជីវភាពរស់នៅប្រចាំថ្ងៃ (១៧) ការអភិវឌ្ឍសហគមន៍ (១៥) ការកាត់បន្ថយគ្រោះមហន្តរាយ និងហានិភ័យ (១១) ការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី (១៦)។ ចំពោះវិស័យដទៃទៀតគឺជាចំនួនដ៏តូចនៅក្នុងរង្វង់ទិន្នន័យ។

*រូប ៤.៤. វិស័យនៃការងារអង្គការ*




### ៤.១.៤. តំបន់គោលដៅនៃកម្មវិធី

ក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ មានកម្មវិធី/គម្រោងដែលកំពុងអនុវត្តការងារនៅទូទាំងខេត្តក្រុងនៃប្រទេសកម្ពុជា។ ដោយឡែកភ្នំពេញ គឺជារាជធានីរបស់ប្រទេសកម្ពុជា ដែលមានការិយាល័យកណ្តាលនៃអង្គការសង្គមស៊ីវិលជាច្រើន ដែលធ្វើអោយទីតាំងសម្រាប់ចំនួនកម្មវិធីគោលដៅចម្បងមានចំនួនច្រើនជាងគេ (៦៨) និងចំនួនបន្តបន្ទាប់មកទៀត ដែលមានតួរលេខខ្ពស់ផងដែរនោះ ស្ថិតនៅ

ក្នុងខេត្តបាត់ដំបង (៥៥) និងខេត្តសៀមរាប (៥០)[1]។ ចំណែកឯចំនួននៃទីតាំងគោលដៅតិចតួចនោះស្ថិតនៅក្នុងតំបន់តូច និងដែលមានអត្រាដង់ស៊ីតេប្រជាជនទាបនោះគឺខេត្តកែប ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ ជាដើម។

*រូប ៤.៥. ទីតាំងអនុវត្តគម្រោង*




## ៤.២. សកម្មភាព និងផលប៉ះពាល់កម្រិតសកម្មភាព និងកម្មវិធី

### ៤.២.១. កម្រិតនៃផលប៉ះពាល់លើកម្មវិធី និងសកម្មភាព

យោងតាមរូប ៤.៣. បានបង្ហាញពីកម្រិតនៃបញ្ហាប្រឈមទៅលើកម្មវិធី និងសកម្មភាព ហើយស្ទើរតែទាំងអស់បានរងផលប៉ះពាល់ជាអវិជ្ជមានដោយសារជំងឺកូវីដ១៩ សម្រាប់ការអនុវត្តកម្មវិធីដែលឈានទៅដល់ការពន្យាពេល ឬក៏មិនអាចធ្វើតាមការគ្រោងទុករបស់ខ្លួនបាន ហើយមានតែ ១ ភាគរយប៉ុណ្ណោះ (២អង្គការ) ស្ថិតក្នុងខេត្តក្រចេះ និងខេត្តកោះកុង ដែលបាននឹងកំពុងធ្វើការ ភាគច្រើននៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ព្រៃឈើ ដែលអាចអនុវត្តការងារបានតាមគម្រោងសកម្មភាព និងផែនការរបស់ខ្លួន។

[1] លទ្ធផលនេះស្របគ្នាផងដែរជាមួយនឹងការសិក្សាស្រាវជ្រាវពីការរួមចំណែករបស់អង្គការសង្គមស៊ីវិល តាមរយៈនៃការអង្កេត និងជំរឿនអង្គការសង្គមស៊ីវិលកាលពីឆ្នាំ២០១២ ក្នុងតំណភ្ជាប់នេះ https://www.ccc-cambodia.org/en/download?file_id=804&action=view&view_file_id=fccc489b12587930d92aad790eb0a9f0e0740534

នៅក្នុងការធ្វើចំណាត់ថ្នាក់ពីកម្រិតនៃផលប៉ះពាល់ចាប់ពី ១ (មិនមានផលប៉ះពាល់ទាំងអស់) ដល់៥ (មានផលប៉ះពាល់ធ្ងន់ធ្ងរ)។ ស្ទើរជិតពាក់កណ្តាលនៃអ្នកឆ្លើយតប បានឱ្យចំណាត់ថ្នាក់ពីផលប៉ះពាល់កម្រិតខ្ពស់ ឬកម្រិត៥ (៤៧%/៧២ អ្នកឆ្លើយតប) ពីជំងឺកូវីដ១៩ និងបន្ទាប់ទៀតដោយលើសពីមួយភាគបីស្ថិតក្នុងផលប៉ះពាល់កម្រិតមធ្យម (កម្រិតកណ្តាល) ឬកម្រិត ៤ (៣៧%)។

*រូប ៤.៦. ផលប៉ះពាល់លើគម្រោងសកម្មភាព និងផែនការ*




### ៤.២.២. បញ្ហាប្រឈមលើកម្មវិធី និងកម្រិតសកម្មភាព

ទម្រង់នៃបញ្ហាប្រឈមមួយចំនួនជារួមគឺពាក់ព័ន្ធនឹងការពន្យាពេលនៃគម្រោង ពីការដែលមិនអាចធ្វើសកម្មភាពតាមផែនការគ្រោងទុក បញ្ហាបុគ្គលិក បញ្ហាមូលនិធិ ជំនួយសម្ភារៈផ្សេងៗសម្រាប់ការឆ្លើយតបបន្ទាន់ សម្ភារដើម្បីបម្រើការងារតាមប្រព័ន្ធអនឡាញ ការតភ្ជាប់បណ្តាញអ៊ីធឺណែត ការខ្វះខាតព័ត៌មាន ការរឹតបន្តឹងការធ្វើដំណើរ ការប្រមូលផ្តុំ និងការជួបប្រជុំ។

ក្នុងចំណោមនោះ បញ្ហាប្រឈមដែលមានប្រេកង់ខ្ពស់ជាងគេ គឺការដែលមិនអាចធ្វើសកម្មភាពតាមផែនការ ដែលនាំអោយមានការពន្យាពេល។ បន្ទាប់មកគឺមានភាពរាំងស្ទះបញ្ហាមូលនិធិ (ថវិកា) ក៏ដូចជាមិនអាចរៀបចំការជួបជុំខ្នាតធំ និងមានការចូលរួមពីសំណាក់អ្នកទទួលផលដោយសារតែការរឹតត្បឹត និងយោងសេចក្តីណែនាំពីសុវត្ថិភាព។

*តារាង៤.១ បញ្ហាប្រឈមលម្អិតលើការងារកម្រិតកម្មវិធី*

| បញ្ហាប្រឈមសម្រាប់កម្រិតកម្មវិធី | ប្រេ្វកង់ |
|---|---|
| មិនអាចអនុវត្តសកម្មភាព និងពន្យាពេលគម្រោង | ៥៩ |
| មិនអនុញ្ញាតសម្រាប់ប្រជុំក្រុម ពីសំណាក់អាជ្ញាធរ ស្របតាមការឆ្លើយតបទៅនឹងសេចក្ដីណែនាំពីសុវត្ថិភាពរបស់ក្រសួងសុខាភិបាល | ១៩ |
| សហគមន៍មានការភ័យខ្លាច និងមិនហ៊ានចូលរួមនៅក្នុងសកម្មភាពកម្មវិធី | ១០ |
| ហានិភ័យខ្ពស់ និងបញ្ហាប្រឈមសម្រាប់បុគ្គលិក | ៩ |
| ការបិទសាលារៀន លំបាកធ្វើការងារក៏ដូចជាការឆ្លើយតបការគាំទ្រតាមតម្រូវការផ្សេងៗ | ៨ |
| កាត់បន្ថយមូលនិធិជំនួយបណ្ដាយមកពីសហគមន៍(ប្រទេស) ម្ចាស់ជំនួយ មានផលប៉ះពាល់ដូចគ្នា | ៦ |
| ធ្វើការពីផ្ទះ និងភាពលំបាកចូលទៅក្នុងកន្លែងសហគមន៍ផ្ទាល់ | ៦ |
| ការរឹតត្បិតការធ្វើដំណើរ និងកំណត់លទ្ធភាពចូលទៅក្នុងសហគមន៍ | ៦ |
| មិនទាន់មានភាពបន្សាំជាមួយនឹងការធ្វើការងារតាមប្រព័ន្ធអនឡាញ | ៥ |
| ខ្វះខាតមូលនិធិជំនួយ (ថវិកា) | ៤ |
| សម្ភារអនាម័យនៅមានកម្រិត | ៣ |
| ខ្វះខាតសម្ភារៈដើម្បីបម្រើការងារតាមប្រព័ន្ធអនឡាញ និងសំណើគាំទ្រផ្សេងៗ | ៣ |
| បុគ្គលិកមួយចំនួនមិនអាចធ្វើការពីផ្ទះ ឧទាហរណ៍អ្នកបើកបរ | ២ |
| មិនអាចចំណាយមូលនិធិតាមការគ្រោងទុក/គម្រោង | ២ |
| ផលិតភាព និងគុណភាពនៃការងារដែលធ្វើការពីផ្ទះនៅមានកម្រិត | ២ |
| ការភ័យខ្លាចនៃការរីកសាយភាយក្នុងចំណោមសហគមន៍ និងភាគីពាក់ព័ន្ធ | ២ |
| បញ្ហាភ្ជាប់បណ្ដាញប្រព័ន្ធអ៊ីធីណែត | ២ |
| ពិបាកទំនាក់ទំនង និងទទួលបានព័ត៌មាន | ២ |
| មិនអាចបង្កើតប្រាក់ចំណូលចេញពីកម្មវិធី | ២ |
| ខ្វះខាតអ្នកជំនាញ និងការចូលរួមពីសំណាក់អាជ្ញាធរ | ២ |

| | |
|---|---|
| ភាពយឺតយ៉ាវនៃការផ្តល់មូលនិធិពីម្ចាស់ជំនួយ | ១ |
| ម្ចាស់ជំនួសមិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរ ឬបង្វិលនៃថវិកា | ១ |
| អ្នកផ្គត់ផ្គង់ សេវាកម្ម និងភាពជាដៃគូជាមួយនឹងអ្នកពាក់ព័ន្ធនៅមានកម្រិត | ១ |
| មិនមានព័ត៌មានច្បាស់លាស់ពីរដ្ឋាភិបាលអំពីគម្រោងការបង្ខាំងមិនឱ្យចេញចូល | ១ |
| ក្រុមអ្នកស្ម័គ្រចិត្តពេលមានភាពបន្ទាន់មួយចំនួនតូច ធ្វើការបន្ថែមម៉ោងនិងបន្ថែមកិច្ចការដើម្បីជួយផ្តល់តាមតម្រូវការចាំបាច់ជាមូលដ្ឋានទៅកាន់ក្រុមគ្រួសារដែលឆ្លងជំងឺ | ១ |
| មិនអាចទៅមើលអ្នកជំងឺតាមរយៈនៃការអនុវត្តការងារពីចម្ងាយ | ១ |
| ភាពមិនប្រាកដនៃផែនការសម្រាប់ជម្រើសនៃការរៀបចំភស្តុភាផ្សេងៗ និងការចំណាយដែលមានតម្លៃខ្ពស់ | ១ |
| មិនមានចម្លើយ | ៣ |

### ៤.២.៣. សកម្មភាពឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាជំនួយទៅកាន់អ្នកទទួលផល

ក្នុងផ្នែកនេះ ស្វែងយល់អំពីការឆ្លើយតប ឬបានធ្វើ សម្រាប់ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាការជួយដល់អ្នកទទួលផល។ សកម្មភាពចម្បងជាច្រើន ត្រូវបានធ្វើឡើងតាំងពីការលើកកំពស់ការយល់ដឹង តាមរយៈការប្រើប្រាស់សម្ភារអប់រំផ្សព្វផ្សាយផ្សេងៗ ក៏ដូចជាព្យាយាមគ្រប់គ្រង និងគាំទ្រជាមួយនឹងការឆ្លើយតបបន្ទាន់សម្រាប់ការការពារដល់ភាគីពាក់ព័ន្ធ។ ការឆ្លើយតបទាំងនេះមានភាពសមស្របសម្រាប់អង្គការ ដែលមានគម្រោងកញ្ចប់ថវិកាសម្រាប់អនុវត្តនលើការងារផ្សេងៗ ខណៈដែលអង្គការដែលមិនមានថវិកាបែបនេះ ស្វែងរកកិច្ចសហការនិងជំនួយពីអង្គការដៃគូរបស់ខ្លួន និងព្យាយាមធ្វើការត្រួតពិនិត្យឡើងវិញពីកម្មវិធីក្នុងស្ថាប័នរបស់ខ្លួន និងវិភាជន៍ថវិកាដ៏សមស្រមសម្រាប់ការឆ្លើយតបពីជំងឺរាតត្បាតនេះ។

***តារាង៤.២. អ្វីដែលបានធ្វើក្នុងការឆ្លើយតប និងការផ្តល់ជំនួយដល់អ្នកទទួលផល***

| **អ្វីដែលបានធ្វើសម្រាប់កម្មវិធីក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ១៩** | **ប្រេកង់** |
|---|---|
| លើកកម្ពស់ការយល់ដឹង ការចែកចាយ និងសម្ភារប្រើប្រាស់ទប់ស្កាត់ផ្សេងៗ | ៤០ |
| រៀបចំការធ្វើការពីចម្ងាយ និងការណែនាំពីសុវត្ថិភាពសម្រាប់បុគ្គលិកនិងដៃគូ | ៣២ |
| ពន្យាពេលសកម្មភាពភាគច្រើន ឬក៏លុបចោលសកម្មភាពទាំងនោះ | ២២ |

| | |
|---|---|
| កាត់បន្ថយការជួបជុំ និងធ្វើតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល/ក្រសួងសុខាភិបាល | ១៦ |
| ផ្តល់នូវសម្ភារៈ និងចែកកញ្ចប់ជំនួយសង្គ្រោះ | ១១ |
| ផ្លាស់ប្តូរវិធីសាស្ត្រធ្វើការ ឧទាហរណ៍ តាមប្រព័ន្ធអនឡាញ និងរក្សាការឆ្លើយតប សម្រាប់ភាពចាំបាច់នៃសហគមន៍/អ្នកទទួលផល | ១០ |
| ពិនិត្យមើលផែនការ និងរៀបចំសកម្មភាពឆ្លើយតបនឹងជំងឺកូវីដ១៩ | ៦ |
| ធ្វើការជាមួយរដ្ឋាភិបាល និងចាត់វិធានការការពារ | ៦ |
| ទំនាក់ទំនងជាមួយនឹងអ្នកទទួលផលអំពីការផ្លាស់ប្តូរ | ៤ |
| ចែករំលែកថវិកាសម្រាប់ការឆ្លើយតប និងបន្តទំនាក់ទំនងជាមួយម្ចាស់ជំនួយ | ៤ |
| មិនបានធ្វើអ្វីជាដុំកំភួននោះទេ ដោយហេតុតែវាកើតឡើងភ្លាមៗ | ៣ |
| អាចធ្វើតាមផែនការ ដោយសារតំបន់គោលដៅនៅដាច់ស្រយាល និងតំបន់ព្រៃ | ២ |
| រៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រដោះស្រាយ | ២ |
| បន្តតាមដានពីការរីករាលដាល និងធ្វើតាមសេចក្តីណែនាំអំពីអនាម័យ | ២ |
| ពិនិត្យគម្រោងឡើងវិញ និងរៀបចំសកម្មភាពថ្មីៗមួយចំនួនដោយបន្តរក្សា គោលដៅ និងលទ្ធផល | ១ |

## ៤.៣. សកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន

### ៤.៣.១. បញ្ហាប្រឈមមុខនៃកម្រិតស្ថាប័ន

ក្នុងផ្នែកសំខាន់នេះបង្ហាញពីសកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន។ ជាលទ្ធផល តាមរយៈរូបខាងក្រោម បង្ហាញពីកម្រិតដែលអាចប្រៀបធៀបគ្នាសម្រាប់បញ្ហាប្រឈមជាមួយ កម្រិតគម្រោងនិងសកម្មភាព ដូចដែលបានរៀបរាប់ខាងលើ។ ជាទូទៅ តិចឬច្រើនស្ទើរតែរាល់អង្គការទាំងអស់បាននឹងប្រឈមបញ្ហា លើកលែងតែអង្គការចំនួន២តែប៉ុណ្ណោះ ដែលអាចធ្វើការតាមការគ្រោងទុកដោយគ្មានការបង្ហាញនូវបញ្ហាប្រឈម ក៏ប៉ុន្តែធ្វើការជាមួយភាពប្រុងប្រយ័ត្នផងដែរ។ ប្រសិនជាមើលពីកម្រិតនៃបញ្ហាប្រឈមវិញ មានចំនួន១៤% (២០ អង្គការ) ដែលស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ ដែលមិនអាចធ្វើសកម្មភាពទាំងអស់ដូចទៅនឹងការគ្រោងទុកនោះឡើយ។

*រូប ៤.៧. បញ្ហាប្រឈមបច្ចុប្បន្នសម្រាប់អង្គការ*




## ៤.៣.២. សកម្មភាពអង្គការ និងការពិចារណាយ៉ាងហ្មត់ចត់ ដើម្បីឆ្លើយតបជំងឺកូវីដ១៩

លទ្ធផលនេះចង្អុលបង្ហាញពីសកម្មភាព និងអ្វីកំពុងពិចារណាយ៉ាងល្អិតល្អន់ ដើម្បីរៀបចំសម្រាប់ការឆ្លើយតបជាលក្ខណៈស្ថាប័ន។ រាល់អ្នកឆ្លើយតបទាំងអស់ បានធ្វើរឿងមួយចំនួន និងពិចារណាយ៉ាងយកចិត្តទុកដាក់ ដើម្បីចាត់វិធានការប្រហាក់ប្រហែល ក្នុងចំណោមប្រភេទចម្លើយផ្សេងៗគ្នាដែលពាក់ព័ន្ធតាំងពីបុគ្គលិក ម្ចាស់ជំនួយ អ្នកទទួលផល និងភាគីពាក់ព័ន្ធផ្សេងៗ។ ក្នុងចំណោមចម្លើយទាំងនោះមាន ៩៤% បានលើកកម្ពស់សេវាសុខភាព និងការអនុវត្តសុវត្ថិភាពសម្រាប់បុគ្គលិក ហើយមាន ៨៨% បានបន្តការជូនដំណឹងទៅកាន់ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធអំពីការផ្លាស់ប្តូរគម្រោង ហើយ ៨៧% បានអនុញ្ញាតឱ្យបុគ្គលិករៀបចំអោយមានភាពបត់បែនសម្រាប់ការអនុវត្តការងារ (ឧទាហរណ៍ ធ្វើការពីផ្ទះ)។

ក្នុងការស្វែងរកដំណោះស្រាយ ឬសកម្មភាពផ្សេងៗ ក្រៅពីនេះ មានត្រឹមតែ ៤% ប៉ុណ្ណោះដែលមានអ្នកឆ្លើយតបផ្សេងៗគ្នាដូចជម្រាបជូនខាងក្រោម៖

- ស្នើសុំមូលនិធិសម្រាប់ការឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ១៩
- រៀបចំគោលនយោបាយបុគ្គលិក និងផែនការបន្តផ្សេងៗ ពាក់ព័ន្ធបុគ្គលិក
- ផ្តល់នូវមូលនិធិពិសេសដើម្បីជួយបុគ្គលិកនិងក្រុមគ្រួសារក្នុងករណីបិទបង្ខាំងការចេញចូល
- ពង្រីកវិសាលភាពនៃការរៀបចំផ្នែកវិជ្ជសាស្ត្រ
- ផ្តល់ជូននូវប្រាក់ខែមុនចំនួនមួយខែសម្រាប់បុគ្គលិក
- អនុញ្ញាតឱ្យបុគ្គលិកអាចយកសម្ភារចាំបាច់ពីការិយាល័យទៅធ្វើការនៅផ្ទះ

*រូប ៤.៨. សកម្មភាពដែលបានធ្វើ និងពិចារណាយ៉ាងហ្មត់ចត់ ដើម្បីចាត់វិធានការ*




## ៤.៣.៣.សកម្មភាពឆ្លើយតប ប្រសិនបើការឆ្លងនៅតែបន្តរហូតដល់រយៈពេលខែ ឬយូរជាងនេះ

គោលបំណងសំណួរនៅក្នុងផ្នែកនេះគឺការទទួលនូវចម្លើយបើក ដែលព្យាយាមដើម្បីទទួលបាននូវការធ្វើសកម្មភាពទាំងឡាយណា ដែលអាចកើតមានឡើងផ្សេងៗគ្នា ក៏ដូចជាទទួលបានគំនិតដើម្បីដោះស្រាយពីការរីកសាយភាយឆ្លងបន្តនៃជំងឺកូវីដ១៩ ប្រសិនបើវានឹងនៅតែបន្តក្នុងរយៈពេលរហូតដល់បីខែទៀត ឬកាន់តែអូសបន្លាយវែងជាងនេះ។

*តារាង ៤.៣. សកម្មភាពឆ្លើយតបកំឡុងពេលជំងឺកូវីដ១៩ ប្រសិនបើវានៅតែបន្តរីកសាយភាយនៅក្នុងរយៈពេលរហូតដល់៣ខែ ឬយូរជាងនេះ*

| លទ្ធភាពឆ្លើយតបក្នុងកំឡុងពេលជំងឺកូវីដ ១៩ | ប្រេកង់ |
|---|---|
| ការលើកឡើងទៅកាន់ម្ចាស់ជំនួយសម្រាប់ការពន្យាពេលសកម្មភាពមួយចំនួន និងពន្យាការចំណាយកញ្ចប់ថវិកា | ១៦ |
| បន្តធ្វើការពីផ្ទះ និងរៀបចំមធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអនឡាញ និងមធ្យោបាយសុវត្ថិភាពសម្រាប់ការងារ | ១៥ |
| មិនប្រាកដនៅឡើយ និងចាំមើល ហើយនឹងធ្វើការពិភាក្សាបន្ថែមទៀតជាមួយក្រុមគ្រប់គ្រងជាន់ខ្ពស់ និងអ្នកពាក់ព័ន្ធសំខាន់ៗ | ១៤ |

| | |
|---|---|
| រៀបចំវិធីសាស្ត្រធ្វើការងារថ្មី ដំណោះស្រាយជាយុទ្ធសាស្ត្រដោយកែសម្រួលអន្តរាគមន៍មួយចំនួន | ១៤ |
| លើកកម្ពស់ការយល់ដឹង សម្ភារផ្សព្វផ្សាយទៅកាន់សហគមន៍អ្នកទទួលផល | ១១ |
| ទំនាក់ទំនងជាមួយនឹងអ្នកទទួលផល/សហគមន៍ ហើយនិងស្វែងរកមធ្យោបាយដើម្បីជួយដល់ពួកគេ | ៧ |
| ព្យាយាមធ្វើការស្របតាមផែនការ និងកំណត់អាទិភាពការងារ ដោយអនុវត្តគោលការណ៍ណែនាំសុវត្ថិភាព | ៥ |
| គ្រប់គ្រងថវិកា សម្រាប់ភាពបន្ទាន់ និងជំនួយមនុស្សធម៌ ទៅកាន់អ្នកទទួលផល និងជនដែលងាយរងគ្រោះ | ៤ |
| ទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធ (ម្ចាស់ជំនួយ អាជ្ញាធរ សហគមន៍ និងដៃគូ) ហើយអាចមានភាពបត់បែនអាស្រ័យទៅលើស្ថានភាព | ៣ |
| កំណត់អ្វីដែលអាចបត់បែន ឬក៏ពន្យាបាន ហើយអនុវត្តតែការងារជាអាទិភាព | ៣ |
| ជួយបន្ថែមទៀតចំពោះសិស្សនិស្សិត លោកគ្រូ-អ្នកគ្រូ ឪពុកម្តាយនៅក្នុងការបង្រៀនកូន និងការហ្វឹកហាត់កូន និងសម្ភារផ្សេងៗទៀត | ២ |
| គម្រោងនឹងត្រូវបានបញ្ចប់ និងមានគម្រោងមួយចំនួនទៀតគឺកំពុងព្យាយាមសម្រេច ឬក៏អាចនឹងឆាប់បិទបញ្ចប់ | ២ |
| ចូលរួមកិច្ចខិតខំប្រឹងប្រែងនៅក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺរាតត្បាត និងធ្វើតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល | ២ |
| ចូលរួមកិច្ចខិតខំប្រឹងប្រែងជាមួយនឹងអង្គការសង្គមស៊ីវិល ជាពិសេសជាកម្រិតថ្នាក់ក្រោមជាតិ ក៏ដូចជាគាំទ្រដល់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន | ១ |
| អាចជួយរាយការណ៍បញ្ជូនករណីឆ្លង ទៅកាន់មន្ទីរពេទ្យ និងទាក់ទងអាជ្ញាធរមូលដ្ឋានសម្រាប់ការជួយយ៉ាងសកម្មចំពោះអ្នកដែលឆ្លងជំងឺ | ១ |
| កាត់បន្ថយការអនុវត្តកម្មវិធីដល់ទៅ៥០% | ១ |
| កាត់បន្ថយការចំណាយតាមលទ្ធភាពដែលអាចធ្វើទៅបាន | ១ |
| គ្រប់បុគ្គលិកបន្តស្នាក់នៅផ្ទះ និងមួយភាគធំនៃប្រាក់ខែត្រូវបានកាត់បន្ថយ | ១ |
| សកម្មភាពកសិកម្មតាមរដូវកាលមួយចំនួនអាចចាំបាច់បន្តធ្វើឡើងវិញ ប្រសិនមិនមានការហាមប្រាម ឬរឹតបន្តឹងពីរដ្ឋាភិបាល | ១ |
| ស្វែងរកហិរញ្ញវត្ថុដើម្បីជួយក្រុមមនុស្សដែលរងផលប៉ះពាល់ | ១ |

**លទ្ធភាពឆ្លើយតបបន្ទាប់ពីជំងឺកូវីដ១៩ (មានការលើកឡើងផ្សេងៗគ្នា)**

- មានគណៈកម្មការសុវត្ថិភាពប្រចាំប្រទេស ដើម្បីជួបពិភាក្សាជាទៀងទាត់ និងពិភាក្សាបន្ថែម
- ត្រួតពិនិត្យឡើងវិញ/លុបចោលសកម្មភាពសំខាន់ៗមួយចំនួន និងបន្តសន្សំលើការចំណាយ
- កាត់បន្ថយបុគ្គលិក និងបន្តរក្សាការទាក់ទងជាមួយនឹងម្ចាស់ជំនួយ
- មានការលំបាកដើម្បីអនុវត្តនូវកម្មវិធីសម្មភាពមួយចំនួន ហើយនឹងចាំបាច់បង្កើតការរៀបចំដទៃទៀតជាមួយនឹងម្ចាស់ជំនួយ
- អាចវិលត្រឡប់មកធ្វើការដូចដើមវិញយោងទៅតាមគម្រោងសកម្មភាព និងរំពឹងថាម្ចាស់ជំនួយនិងយល់ពីបញ្ហាទាំងនេះ
- បានរៀបចំអ្វីដែលជាការឆ្លើយតបរួចរាល់ទៅនឹងផលប៉ះពាល់នេះសម្រាប់រយៈពេល៦ខែ
- បន្តធ្វើសកម្មភាពការពារ ដូចជាការផ្សព្វផ្សាយឱ្យមានការយល់ដឹងបន្ថែម ទំនាក់ទំនងបន្ទាន់ (នគរបាល សង្កាត់ មណ្ឌលសុខភាព) ផ្តល់នូវសម្ភារៈការពារដូចជា ម៉ាស់ អាកុល សាប៊ូលាងដៃ ជាដើម ហើយនិងកញ្ចប់ស្បៀងសង្គ្រោះ (អាហារស្ងួត និងកំប៉ុង)
- បន្តការទាក់ទងនិងតាមដានជាមួយអ្នកទទួលផល ដើម្បីផ្តល់ការលើកទឹកចិត្ត និងជំនួយចាំបាច់ តាមលទ្ធភាពដែលអាចធ្វើបាន
- រៀបចំសម្រាប់ការបណ្តុះបណ្តាលលើបញ្ហាតានតឹង និងបញ្ហាផ្លូវចិត្តផ្សេងៗ ទៅកាន់អ្នកទទួលផលដើម្បីដោះស្រាយក្រោយពេលនៃការរាតត្បាត
- ពង្រឹងផ្នែកចិត្តសាស្រ្តរបស់បុគ្គលិកល្អប្រសើរឡើងវិញ និងការងាយសម្របខ្លួន-ពិចារណាពីការប្រតិបត្តិការ ព្យួរការប្រកាសរើសបុគ្គលិកលើតួនាទីមួយចំនួនមិនសូវចាំបាច់
- គ្រោងជួយទ្រទ្រង់ និងស្តារជីវភាពរស់នៅអោយមានភាពប្រសើរឡើងវិញ រួមទាំងប្រាក់ចំណូល
- ជួយគាំទ្រអង្គការសង្គមស៊ីវិលមូលដ្ឋាន ដើម្បីពង្រឹង និងធ្វើឱ្យមានភាពល្អប្រសើរលើស្ថានភាពសង្គមសេដ្ឋកិច្ច
- ផ្តោតការយកចិត្តទុកដាក់បន្ថែមលើជំនួយឧបត្ថម្ភសម្រាប់ស្ថានភាពគ្រីក្រខ្លាំង
- ព្យាយាមសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានទៅតាមលទ្ធភាព ដែលអាចធ្វើបានដើម្បីសម្រេចគម្រោងសកម្មភាពនៅពេលស្ថានភាពល្អប្រសើរវិញ
- បង្កើនសកម្មភាពហ្វឹកហាត់ទ្វេដងនៅក្នុងសហគមន៍
- វិលត្រឡប់ទៅកាន់រាល់មេរៀនកំឡុងពេលនៃដើមវិស្សមកាលរបស់ពួកគេ ដើម្បីធ្វើឱ្យប្រាកដថា សិស្សទាំងអស់បានយល់ដឹងច្បាស់ពីមេរៀន

- ធ្វើសម្រង់ស្ទង់មតិបន្ទាប់ពីស្ថានភាពវិលត្រឡប់ល្អដូចដើមវិញ ដើម្បីមើលឱ្យឃើញថានរណា ដែលត្រូវការជំនួយបន្ថែមទៀត ហើយនិងផ្តល់កញ្ចប់អាហារបន្ថែមក្នុងករណីចាំបាច់

## ៥.៣.៥. គណនេយ្យភាពសម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងអ្នកទទួលផល ប្រសិនបើបន្តការឆ្លង

នៅក្នុងផ្នែកនេះ គឺជាប្រភេទសំណួរបើក សម្រាប់រាល់ចម្លើយទាំងអស់ ដែលព្យាយាមដើម្បីទទួលបាននូវរាល់លទ្ធភាពផ្សេងៗ ក៏ដូចជាគំនិតទាំងឡាយណា សម្រាប់លើកឡើងមកដោះស្រាយបញ្ហាគណនេយ្យភាពសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា បុគ្គលិក ម្ចាស់ជំនួយ និងដៃគូមូលនិធិ ព្រមទាំងអ្នកទទួលផល ប្រសិនបើជំងឺកូវីដ១៩នេះ នៅតែបន្តកើតមានរីកឆ្លងក្នុងរយៈពេល៣ខែក្រោយទៀត ឬយូរជាងនេះ។ មានអ្នកឆ្លើយតបជាច្រើនមិនទាន់បានចែករំលែកការឆ្លើយតបរបស់ពួកគេនៅឡើយ ឬក៏មិនទាន់មានគំនិតនៅឡើយ ហើយត្រូវការការពិភាក្សាលម្អិតបន្ថែមជាមួយនឹងអ្នកសម្រេចចិត្តសំខាន់ៗ ឬក៏រង់ចាំមើល និងរៀនសូត្រពីលទ្ធផលនៅក្នុងសិក្សានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួននៃអង្គការជាច្រើនបានចែករំលែកលទ្ធភាពនៃដំណោះស្រាយ និងសកម្មភាពឆ្លើយតបទៅនឹងគណនេយ្យភាពទៅកាន់អ្នកដើរតួពាក់ព័ន្ធផ្សេងៗគ្នា ហើយមានភាពចម្រុះគ្នានៃគំនិត និងលទ្ធភាពដំណោះស្រាយ ដែលបានប្រមូលផ្តុំឡើង ហើយវិភាគច្របាច់បញ្ចូលគ្នាដូចចំណុចខាងក្រោមនេះ។

| គណនេយ្យភាពបុគ្គលិក ប្រសិនបើការឆ្លងនៅតែបន្តនៅក្នុងរយៈពេល៣ខែក្រោយ |
|---|
| - រៀងរាល់បុគ្គលិកដែលមិនមានការងារដែលទទួលខុសត្រូវសំខាន់ នឹងមានការចរចារដើម្បីផ្អាកកុងត្រាការងារ ដែលជាជម្រើសចុងក្រោយ។ ប៉ុន្តែបើសិនជាម្ចាស់ជំនួយនៅតែអាចទ្រាំទ្រលើប្រាក់ខែបុគ្គលិកបាន ឬក៏ចុងបញ្ចប់ត្រូវព្យួរការងារដោយមិនទទួលបានកម្រៃ |
| - ត្រៀមសម្រាប់ភាពបត់បែន ប្រសិនបើនៅតែបន្តការងារធ្វើពីផ្ទះ ឬក៏ប្រាក់ខែរបស់បុគ្គលិកត្រូវបានកាត់បន្ថយពីកញ្ចប់ថវិកាដែលមាន |
| - ពិភាក្សា និងពិនិត្យគម្រោងឡើងវិញ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រការងារថ្មី |
| - នៅតែបន្តបើកប្រាក់ខែជូនបុគ្គលិក ពីព្រោះពួកគេនៅតែកំពុងធ្វើការងារពីចម្ងាយ តែត្រូវមានគម្រោងផែនការការងារច្បាស់លាស់ ដើម្បីបញ្ជូនទៅកាន់ប្រធានគ្រប់គ្រងផ្ទាល់ |
| - ដរាបណាម្ចាស់ជំនួយមានបំណងនឹងបន្តផ្តល់មូលនិធិជំនួយ យើងនឹងនៅតែអាចរៀបចំចាត់ចែងបើកប្រាក់ខែជូនបុគ្គលិកពេញ ១០០% |
| - បន្តរក្សាការធ្វើការពីចម្ងាយ និងការទំនាក់ទំនង ឬក៏កាត់បន្ថយ ចំនួន៥០% ឬតិចជាងនេះ នៃប្រាក់ខែ និងអត្ថប្រយោជន៍របស់បុគ្គលិក |

- បុគ្គលិកទាំងអស់អាចឈប់សម្រាកដោយមិនទទួលបានប្រាក់ខែ លើកលែងតែបុគ្គលសំខាន់ៗ
- ការកាត់បន្ថយចំនួនបុគ្គលិក ដោយអនុលោមទៅតាមច្បាប់ការងារ
- បុគ្គលិកអាចចាកចេញ ដោយគ្មានការបង់ជូន និងអាចបន្តរក្សាការងារតាមប្រព័ន្ធអនឡាញ
- គ្រប់គ្រងការងារក្រៅម៉ោងសម្រាប់បុគ្គលិក
- បើសិនជាមិនមានការជួយគាំទ្រពីម្ចាស់ជំនួយទេ រក្សាតែបុគ្គលិកណាសំខាន់ និងផ្នែកប្រតិបត្តិការដែលចាំបាច់

## គណនេយ្យភាពម្ចាស់ជំនួយ បើសិនការឆ្លងនៅតែបន្តមានក្នុងរយៈពេល៣ខែក្រោយ

- ពិគ្រោះយោបល់ជាមួយនឹងដៃគូហិរញ្ញវត្ថុ ពិនិត្យសកម្មភាពគម្រោងឡើងវិញ ដែលអាចអនុវត្ត និងសម្របទៅនឹងផលប៉ះពាល់ពីស្ថានភាពជំងឺកូវីដ១៩
- លើកឡើងទៅកាន់ម្ចាស់ជំនួយ និងដៃគូហិរញ្ញវត្ថុសម្រាប់ពន្យាពេល និងជួយគាំទ្រលើប្រាក់ខែបុគ្គលិក
- ស្នើសុំទៅកាន់ម្ចាស់ជំនួយសម្រាប់ការពន្យាផែនការ អត្ថប្រយោជន៍បុគ្គលិកនឹងត្រូវយកមកពិចារណាដើម្បីប្រើប្រាស់យុទ្ធសាស្រ្តក្នុងការកាត់បន្ថយភាគរយមួយចំនួន និងស្នើសុំបន្តគាំទ្រខ្លះៗពីម្ចាស់ជំនួយ
- បន្តធ្វើបច្ចុប្បន្នភាពឱ្យម្ចាស់ជំនួយបានដឹងអំពីស្ថានភាព ហើយពួកគេនឹងយល់ដូចអ្វីបានកើតឡើងដោយហេតុតែមានផលប៉ះពាល់គ្រប់ប្រទេស
- ចរចារជាមួយនឹងម្ចាស់ជំនួយដើម្បីបន្តរក្សាចំនួនបុគ្គលិក ពីព្រោះនេះគឺជាបញ្ហាសាកល
- អនុវត្តការសន្សំចំណាយ និងបង្អាករាល់ការចំណាយទៅលើបេសកកម្មណាដែលមិនមែនជាកិច្ចការស្នូល
- ស្នើសុំសម្រាប់ពេលវេលានូវរាល់ការអនុវត្តគម្រោង
- ការផ្អាកជាបណ្តោះអាសន្ននូវតួនាទីមួយចំនួន និងបង្ហាញពីគណនេយ្យសន្សំ សម្រាប់បុគ្គលិកដែលគួរតែមានជម្រើស
- នឹងស្នើសុំម្ចាស់ជំនួយសម្រាប់បន្តរយៈពេលការងារ ហើយប្រាក់ខែនៅតែបើកជូនរាល់គ្រប់បុគ្គលិកទាំងអស់

- នៅតែចាំបាច់ទទួលការជួយពីម្ចាស់ជំនួយសម្រាប់ប្រាក់ខែបុគ្គលិកដោយពួកគេ នៅតែបន្តធ្វើការពីផ្ទះ
- មូលនិធិជំនួយភាគច្រើននឹងត្រូវបានបដិសេធប្រើប្រាស់ពីព្រោះម្ចាស់ជំនួយក៏កំពុងប្រឈមនឹងបញ្ហានេះដែរ
- រៀបចំរាល់ធនធាន ហើយជូនដំណឹងទៅម្ចាស់ជំនួយនូវអ្វីដែលពួកយើងកំពុងប្រឈម
- លើកឡើងទៅម្ចាស់ជំនួយនិងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពន្យាពេលការអនុវត្ត ស្នើសុំការបន្លាយពេលវេលាបន្ថែមបើសិនវាជាករណីចាំបាច់ ឬក៏មានការប្រែប្រួលសកម្មភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការភ្លាមៗបណ្តាលមកពីវិបត្តិនេះ

### គណនេយ្យភាពអ្នកទទួលផល បើសិនបើការឆ្លងនៅតែបន្តក្នុងរយៈ៣ខែក្រោយ

- នៅតែបន្តជួយផ្តល់នូវតម្រូវការចាំបាច់រហូតទាល់តែពួកយើងមិនអាចទៅខាងក្រៅដើម្បីផ្តល់សេវាកម្មបាន និងបន្ទាប់មកពួកយើងនឹងជូនដំណឹងប្រសិនបើបញ្ឈប់កម្មវិធី
- សម្លឹងមើលពីជម្រើសធ្វើការផ្សេងទៀត ដើម្បីអាចបន្តនូវប្រតិបត្តិការ និងហិរញ្ញវត្ថុ
- មិនទាន់ច្បាស់លាស់នៅឡើយត្រង់ចំនុចនេះ វាជាការល្អដែលបានលឺពីរដ្ឋាភិបាល និងម្ចាស់ជំនួយសំខាន់ៗនូវអ្វីដែលពួកគេណែនាំដល់ពួកយើង
- ពន្យាពេលជាបណ្តោះអាសន្ន ធ្វើការជាមួយអ្នកទទួលផល
- រៀបចំបុគ្គលិក ធ្វើការងារបែបគំរូឆ្លាតវៃតាមលទ្ធភាពដែលអាចធ្វើបាន ហើយនឹងកែប្រែសកម្មភាពដែលអាចធ្វើបានមួយចំនួនដូចជា ការប្រជុំ សិក្ខាសិលា តាមប្រព័ន្ធអនឡាញជាមួយនឹងអ្នកពាក់ព័ន្ធ និងអ្នកទទួលផល

## ៥. សំណូមពរ និងយោបល់ផ្សេងៗ

យោបល់ និងសំណូមពរផ្សេងៗ ត្រូវបានច្របាច់បញ្ចូលដូចមានខាងក្រោមនេះ ដែលបានលើកឡើងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ។

### ៥.១. សម្រាប់ អង្គការ គ.ស.ក

| សម្រាប់អង្គការ គ.ស.ក | ប្រេកង់ |
|---|---|
| **ចែករំលែកព័ត៌មាន** | |
| ✚ ចែករំលែកព័ត៌មានទៀងទាត់ និងផ្តល់ដំបូន្មានទាន់ពេលវេលា (ផ្នែកច្បាប់ ស្ថានភាពជំងឺកូវីដ១៩ និងពីផលប៉ះពាល់របស់វាជាដើម) តាមរយៈវេទិកាតាមប្រព័ន្ធអនឡាញ | ៥០ |
| ✚ ចែករំលែកព័ត៌មានពីការប្រឈម បញ្ហានិងក្តីព្រួយបារម្ភរបស់អង្គការសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាល ទៅកាន់រដ្ឋាភិបាល ជាពិសេសនោះគឺម្ចាស់ជំនួយ (ប្រាក់ខែ និងអត្ថប្រយោជន៍បុគ្គលិក កំឡុងពេលនៃស្ថានភាពនេះ ការកែសម្រួលថវិកាឡើងវិញ។ល។) | ១៧ |
| ✚ ផ្តល់ការជួយគាំទ្រ និងចែករំលែកព័ត៌មានទៅកាន់បណ្តាញអង្គការមិនមែនរដ្ឋាភិបាលតាមបណ្តាខេត្ត និងអង្គការសហគមន៍មូលដ្ឋានពីកូវីដ១៩ អោយទាន់ពេលវេលា | ៦ |
| ✚ ធ្វើការសម្របសម្រួល ដើម្បីចែករំលែកព័ត៌មានពីសមាជិក និងបន្តធ្វើបច្ចុប្បន្នភាពអំពីជំងឺកូវីដ១៩ | ១ |
| **គៀរគរធនធាន និងការជួយគាំទ្រ** | |
| ✚ គៀរគរធនធានដើម្បីជួយគាំទ្រ ក្រុមគោលដៅ និងសហគមន៍ ដែលស្ថិតនៅក្នុងស្ថានភាពនៃជំងឺកូវីដ១៩ (តាមរយៈគាំទ្រផ្តល់មូលនិធិទៅកាន់សមាជិកអង្គការមិនមែនរដ្ឋាភិបាល) | ២២ |
| ✚ ផ្តល់នូវ ឧបករណ៍ដែលអាចដាក់ដំណើរការបាន ដើម្បីជំនួយកម្មវិធីរៀនសូត្រសម្រាប់អង្គការមិនមែនរដ្ឋាភិបាលតូចៗ ដែលត្រូវការចាំបាច់ (ទូរស័ព្ទទាក់ទង កុំព្យូទ័រយួរដៃ ដែលអាចបន្តជួយការងារ និងគម្រោងរបស់ពួកគេ) | ១ |
| ✚ ធ្វើការសម្របសម្រួលគាំទ្រពីសមាជិក ដើម្បីដោះស្រាយបញ្ហាផ្សេងៗ | ១ |
| **ជំនួយជាសម្ភារៈអនាម័យ និងសម្ភារអប់រំផ្សេងៗ** | |
| ✚ ចែករំលែកសារសម្រាប់ការការពារ និងសម្ភារផ្សព្វផ្សាយដូចជា ផ្ទាំងរូបភាព ខិតប័ណ្ណ ឯកសារផ្សេងៗ។ល។ | ១៣ |

| | |
|---|---|
| ✦ ការចែកចាយនូវសម្ភារៈអនាម័យ (ម៉ាស់ ជែល អាកុល ឧបករណ៍វាស់កំដៅជាដើម) | ៨ |
| **ការរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព** | |
| ✦ រៀបចំព្រឹត្តិការណ៍កសាងសមត្ថភាព និងវេទិកាតាមប្រព័ន្ធអនឡាញ | ៧ |
| ✦ ចែករំលែកលទ្ធផលពីការធ្វើសម្រង់មតិមកវិញ ( ផលប៉ះពាល់ពីជំងឺកូវីដ១៩ ទៅលើការងារអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា) | ៧ |
| ✦ អំពាវនាវសម្រាប់ការប្រជុំជាមួយនឹងដៃគូសម្រាប់ការពិភាក្សា និងរៀនសូត្រ ដើម្បីស្វែងរកនូវដំណោះស្រាយប្រសើរ ជាពិសេសនោះសម្រាប់បុគ្គលិកនិងអ្នកទទួលផល | ៦ |
| ✦ ផ្តល់ជូននូវការហ្វឹកហាត់ ការបង្រៀន និងឧបករណ៍រៀនសូត្រតាមរយៈប្រព័ន្ធអនឡាញ ទៅកាន់សាលារដ្ឋ ដើម្បីបន្តការរៀនសូត្ររបស់សិស្សក្នុងកំឡុងពេលជំងឺកូវិដ១៩ | ១ |
| ✦ ការសម្របសម្រួលតាមវិស័យផ្សេងៗ ដើម្បីទាញចេញនូវសកម្មភាពផ្សេង ឬថាតើគួរឆ្លើយតបរបៀបណា | ១ |
| **ផ្នែកច្បាប់ ការជួយគាំទ្រ និងពន្ធ** | |
| ✦ ចែករំលែកព័ត៌មានទៀងទាត់ និងផ្តល់ដំបូន្មានទៅលើវស័យផ្នែកច្បាប់ | ៣០ |
| ✦ គួរតែពិភាក្សាជាមួយនឹងរដ្ឋាភិបាល ដើម្បីគិតគូសម្រាប់និន្នាការពេលអនាគត បើសិនជាករណីនេះអាចកើតឡើងម្តងទៀត ហើយស្នើសុំមូលនិធិមួយចំនួនដើម្បីរួមក្នុងការអនុវត្តការដល់អង្គកាសង្គមស៊ីវិល | ៥ |
| ✦ ការលើកលែងពន្ធគួរតែស្នើសុំទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥ |
| ✦ ជំនួយផ្សេងៗផ្នែកច្បាប់ | ៣ |
| **ការសិក្សាស្រាវជ្រាវ និងការវាយតម្លៃ** | |
| ✦ វាយតម្លៃលើផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅកាន់រដ្ឋាភិបាល និងម្ចាស់ជំនួយ | ៤ |
| ✦ គួរតែសិក្សា និងវិភាគលើច្បាប់ថ្មីក្នុងការគ្រប់គ្រងពេលដាក់ប្រទេសជាតិក្នុងភាពអាសន្ន ដែលទាក់ទងទៅនឹងបរិបទនៃច្បាប់ ហើយនឹងពីរបៀបដែលអាចធ្វើការតស៊ូមតិ | ២ |
| ✦ បង្កើតចេញជាករណីសិក្សានៃផលប៉ះពាល់ជំងឺកូវីដ១៩ចំពោះសហគមន៍ និងសង្គម | ១ |

| | |
|---|---|
| **យន្តការការងារសម្រាប់អង្គការ សហគមន៍ និងអ្នកទទួលផល ព្រមទាំងអ្នកពាក់ព័ន្ធកំឡុងពេល និង បន្ទាប់ពីជំងឺកូវីដ១៩** | |
| - គួរតែលើកឡើងពីវិធីសាស្ត្រនៃមធ្យោបាយទំនាក់ទំនង និងគ្រប់គ្រង នៃការធ្វើការពីចម្ងាយ | ៣ |
| - បន្តនូវការប្រមូលផ្តុំនូវសំឡេងសង្គមស៊ីវិល និងបន្តគាំទ្រដល់រដ្ឋាភិបាលដែលជាដៃគូអភិវឌ្ឍន៍ | ៣ |
| - បង្កើតគណៈកម្មការ នៃជំងឺកូវីដ១៩ សម្រាប់ការពិគ្រោះយោបល់ | ២ |
| - យន្តការ ជួយទៅកាន់សហគមន៍ និងសង្គមបន្ទាប់ពីជំងឺកូវីដ១៩ | ២ |
| - ពិចារណាពីសេចក្តីណែនាំ ឬជំនួយផ្នែកច្បាប់ទៅកាន់សមាជិកភាពអង្គការមិនមែនរដ្ឋាភិបាលអំពីការគ្រប់គ្រងបុគ្គលិកកំឡុងពេលការរីកសាយភាយឆ្លងជំងឺកូវីដ១៩ ខណៈដែលបុគ្គលិកមិនចុះធ្វើការងារបានឬមិនមានបន្ទុកការងារ និងការពិចារណាសម្រាប់ការគាំទ្រប្រាក់ខែ | ២ |
| - គួរតែមានលិខិតរួមគ្នា ដើម្បីបើកបង្ហាញ/អំពាវនាវទៅកាន់ម្ចាស់ជំនួយ ដើម្បីកុំទាន់បញ្ចប់កុងត្រា/សកម្មភាព ដែលអាចផ្តល់ផលអាក្រក់ខ្លាំងដល់ការចំណាយលើបុគ្គលិក | ១ |
| - បើសិនជា ការរីកសាយភាយឆ្លងនៅតែបន្តក្នុងរយៈពេល៣ខែ ឬវែងជាងនេះ និង ពិចារណាពីគណនេយ្យភាពចំពោះបុគ្គលិក ស្ថាប័ន និងម្ចាស់ជំនួយ | ៤ |
| **ការភ្ជាប់បណ្តាញ និងការសហការគ្នា** | |
| - កសាងបណ្តាញជាមួយនឹងអង្គការសុខភាពពិភពលោក ភ្នាក់ងារកម្មវិធីជំនួយអភិវឌ្ឍរបស់សហរដ្ឋអាមេរិក អង្គការសហប្រជាជាតិសម្រាប់ទ្រទ្រង់កុមារ និង មជ្ឈមណ្ឌលសម្រាប់គ្រប់គ្រងនិងការពារជំងឺឆ្លង ដើម្បីបញ្ឈប់ការឆ្លង | ១ |
| **ផ្សេងៗទៀត** | |
| - ការលើកលែងបង់ប្រាក់ចូលជាសមាជិកភាពរបស់អង្គការ គ.ស.ក នៅក្នុងឆ្នាំ ២០២០ | ១ |
| - មិនមានចម្លើយ | ២៣ |

## ៥.២. សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ

| សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ | ប្រេកង់ |
|---|---|
| អនុញ្ញាតដល់ការពន្យាពេលអនុវត្តគម្រោង និងការកែសម្រួលអន្តរាគមន៍ | ៦២ |
| ការពិគ្រោះយោបល់ជាមួយនឹងម្ចាស់ជំនួយ ដើម្បីស្វែងរកជម្រើស/ ដំណោះស្រាយលើរបៀបអនុវត្តគម្រោង និងជំនួយទៅកាន់ក្រុមគោលដៅ កំឡុងពេលជំងឺកូវីដ១៩ | ៤២ |
| បង្កើនជំនួយមូលនិធិ ដើម្បីគាំទ្រប្រតិបត្តិការ និងសហគមន៍ ជាពិសេស នោះគឺតំបន់ដាច់ស្រយាល | ៤១ |
| អនុញ្ញាតសម្រាប់ប្រាក់ខែបុគ្គលិក និងអត្ថប្រយោជន៍ពេញលេញកំឡុង ពេលជំងឺកូវីដ១៩ | ១៩ |
| ផ្តល់នូវជំនួយមូលនិធិលើសង្គ្រោះបន្ទាន់ អនាម័យ និងសម្ភារអនាម័យដូច ជា ម៉ាស់ អាល់កុល ដែល សាប៊ូដុំ និងឧបករណ៍វាស់កម្តៅ ។ល។ | ១៧ |
| បន្តការចែករំលែកព័ត៌មាន ទំនាក់ទំនងយ៉ាងកក់ក្តៅតាមប្រព័ន្ធអនឡាញ និងការសម្រេចចិត្តនៅក្រោមស្ថានភាពនៃជំងឺកូវីដ១៩ | ៩ |
| គួរតែមានគោលនយោបាយច្បាស់លាស់សម្រាប់គាំទ្រជំនួយមូលនិធិ ក្នុង កំឡុងពេល និងក្រោយពេលជំងឺកូវីដ១៩ | ៨ |
| រៀបចំគម្រោងសម្រាប់ដំណាក់កាលក្រោយជំងឺកូវីដ១៩ | ២ |
| របៀបបង្កើតកម្មវិធីធ្វើការពីចម្ងាយ និងរបៀបឱ្យមនុស្សត្រឡប់មកធ្វើការ ធម្មតាវិញប្រកបដោយប្រសិទ្ធភាព | ១ |
| ផ្តល់នូវការរៀបចំកម្មវិធីដែលមានភាពបត់បែន ឬពង្រឹងអំណាចដល់អ្នក ប្រើប្រាស់មូលនិធិ សម្រាប់ការកែច្នៃកម្មវិធីដែលអាចសម្របទៅនឹងស្ថាន ការណ៍ ដរាបណាវាឆ្លើយតបទៅនឹងគោលដៅ និងវត្ថុបំណង នៃរបៀបវារៈសម្រាប់ការអភិវឌ្ឍ និងអ្នកផ្តល់មូលនិធិ | ១ |
| រៀបចំសម្រាប់ការផ្លាស់ប្តូរសកម្មភាព គម្រោងដើម្បីផ្តល់ជំនួយសម្រាប់អ្នក ដែលទទួលរងផលប៉ះពាល់ | ១ |
| មិនមានចម្លើយ | ១៤ |

## ៥.៣. សម្រាប់រាជរដ្ឋាភិបាល

| សម្រាប់រដ្ឋាភិបាល | ប្រេកង់ |
|---|---|
| ផ្តល់នូវសកម្មភាពសមរម្យ ដើម្បីបន្តរក្សាប្រទេសឱ្យមានសុវត្ថិភាព និងគោលការណ៍ណែនាំច្បាស់លាស់ | ៣០ |
| ផ្តល់នូវជំនួយអាហារទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ ជាពិសេសនោះពលរដ្ឋស្ថិតក្នុងតំបន់ដាច់ស្រយាល | ២៩ |
| បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ | ២៦ |
| ធ្វើបច្ចុប្បន្នភាព និងចែករំលែកព័ត៌មានដោយតម្លាភាព និងជឿទុកចិត្តអំពីជំងឺកូវីដ១៩ ហើយនិងផលប៉ះពាល់របស់វានៅក្នុងប្រទេសកម្ពុជា | ២៣ |
| ផ្តល់នូវមូលនិធិជំនួយទៅកាន់អង្គការមិនមែនរដ្ឋាភិបាល | ១៨ |
| អគ្គនាយកដ្ឋានពន្ធដារគួរតែលើកលែងការយកពន្ធលើប្រាក់ខែ និងពន្ធកាត់ទុក | ១៦ |
| ការចែកចាយនៃការការពារ សម្ភារ:អនាម័យ ទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ | ១៥ |
| សកម្មភាពចាំបាច់បន្ទាន់ លើការជួយលើកកម្ពស់ផ្នែកសេដ្ឋកិច្ច ខណៈពេលដែលមានចំនួនអ្នកជួបការលំបាកកើនឡើងច្រើន បណ្តាលមកពីបាត់បង់ការងារ | ១៣ |
| រៀបចំគោលលនយោបាយសម្រាប់កាត់បន្ថយហានិភ័យ សម្រាប់បុគ្គលិកមិនមែនរដ្ឋ និងផែនការគាំទ្រផ្សេងៗ ខណ:ពេលដែលប្រទេសមួយចំនួនកំពុងតែធ្វើ | ១០ |
| បង្កើនការចែករំលែក និងយល់ដឹងពីជំងឺកូវីដ១៩ ហើយនិងការការពារ ជាពិសេសនោះតំបន់ជនបទ | ១២ |
| បង្កើនការធ្វើតេស្តជំងឺកូវីដ១៩ នូវរាល់អ្នកដែលជាប់សង្ស័យទាំងអស់ (ក្នុងទ្រង់ទ្រាយធំ) | ៧ |
| រក្សាតម្លៃសមរម្យលើទីផ្សារនៃការការពារ និងសម្ភារអនាម័យដូចជា ម៉ាស់ អាកុល ជែល និងឧបករណ៍វាស់កម្តៅ ។ល។ | ៦ |

| | |
|---|---|
| កាត់បន្ថយតម្លៃបង់ភ្លើងអគ្គិសនី និងតម្លៃផ្គត់ផ្គង់ប្រព័ន្ធទឹក | ៤ |
| បើកសិទ្ធិសេរីភាពដល់ប្រជាជនក្នុងការបញ្ចេញមតិ លើជំងឺកូវីដ១៩ | ៤ |
| ពន្យាពេលនៃការបង់ប្រាក់កម្ចី ទៅកាន់ មីក្រូហិរញ្ញវត្ថុ /ធនាគារ | ៣ |
| ពន្យាពេលនៃការបង់ប្រាក់ទៅកាន់ មូលនិធិជាតិរបបសន្តិសុខសង្គម | ៣ |
| ជំនួយសម្ភារការពារគ្រប់គ្រាន់ និងឧបករណ៍ពេទ្យទៅកាន់មន្ទីរពេទ្យ និងបុគ្គលិក | ៣ |
| មិនអនុញ្ញាតឱ្យជនបរទេសចូលមកក្នុងប្រទេសកម្ពុជា | ២ |
| ផ្តល់នូវការព្យាបាលដ៏ប្រសើរចំពោះប្រជាជនដែលមានភាពវិជ្ជមាននៃជំងឺកូវីដ១៩ | ២ |
| ផ្តល់នូវការជួយពិសេសទៅកាន់មីក្រូ សហគ្រាស ដែលស្ថិតក្នុងកំឡុងពេលនេះ ដើម្បីឆ្លើយតបទៅនឹងការបង់ប្រាក់កម្ចី និងប្រតិបត្តិការ | ២ |
| បង្កើតនូវសេចក្តីរាយការណ៍ប្រព័ន្ធអនឡាញទៅកាន់ មូលនិធិជាតិរបបសន្តិសុខសង្គម អគ្គនាយកដ្ឋានពន្ធដារ ។ល។ | ១ |
| ចត្តាឡីស័កខ្លួនឯង គួរតែមានរយៈពេលយូរជាងនេះ ដោយមានការតាមដាន និងឧបត្ថម្ភផ្សេងៗ | ១ |
| មិនមានចម្លើយ | ១៧ |

## ឧបសម្ព័ន្ធ១: គម្រោងសំណួរសម្រាប់ស្ទង់មតិ

| ID: | | | |
|---|---|---|---|

*(សម្រាប់អង្គការ គ.ស.ក)*

# បញ្ជីសំណួរ

## ការស្ទង់មតិរបស់សង្គមស៊ីវិល សម្រាប់សកម្មភាព និងផលប៉ះពាល់ពីជំងឺកូវីដ ១៩

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក.) ធ្វើការស្ទង់មតិនេះជាមួយអង្គការសមាជិក បណ្តាញអង្គការខេត្ត អង្គការសហគមន៍មូលដ្ឋាន និងដៃគូផ្សេងៗ ដែលធ្វើការជាមួយគម្រោងអង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់សកម្មភាពនៃការឆ្លើយតប និងផលប៉ះពាល់ពាក់ព័ន្ធកម្មវិធី ស្ថាប័ន ក៏ដូចជាក្រុមគោលដៅផ្សេងៗ។

*សូមចំណាយពេលប្រមាណ១០នាទីសម្រាប់ការឆ្លើយតប ហើយព័ត៌មានទាំងនេះនឹងត្រូវប្រើសម្រាប់ការវិភាគទិន្នន័យរួម។*

*អរគុណជាមុនសម្រាប់ការចូលរួម។*

| **1. ព័ត៌មានទូទៅ** | |
|---|---|
| 1.1. ឈ្មោះអង្គការ | ………………………………………………………………… |
| 1.2.ប្រភេទអង្គការ | a. អង្គការសហគមន៍មូលដ្ឋាន<br>b. អង្គការក្នុងស្រុក<br>c. អង្គការបរទេស<br>d. ផ្សេងៗ *(សូមបញ្ជាក់)*…… |
| 1.3.វិស័យការងារចំបងក្នុងអង្គការ (អប់រំ សុខភាព…) | ………………………………………………………………… |
| 1.4.តួនាទីរបស់អ្នកផ្តល់ចម្លើយ | a. ថ្នាក់ដឹកនាំ/ថ្នាក់គ្រប់គ្រងជាន់ខ្ពស់<br>b. មន្ត្រីកម្មវិធី<br>c. មន្ត្រីប្រតិបត្តិ<br>d. ផ្សេងៗ*(សូមបញ្ជាក់)*…… |
| 1.5.ប្រភេទក្រុមគោលដៅធ្វើការជាមួយ *(ចម្លើយលើសពីមួយ)* | a. កុមារ<br>b. យុវជន<br>c. មនុស្សចាស់<br>d. ជនពិការ<br>e. ពលរដ្ឋទូទៅ<br>f. ផ្សេងៗ*(សូមបញ្ជាក់)*…… |
| 1.6.ខេត្ត/រាជធានីសម្រាប់កម្មវិធី | a. ភ្នំពេញ<br>b. ខេត្ត *(សូមបញ្ជាក់ទាំងអស់)*… |

| 2. សកម្មភាព និងផលប៉ះពាល់លើផែនការ និងសកម្មភាពការងាររបស់អ្នក | |
|---|---|
| 2.1. តើជំងឺកូវីដ១៩ ធ្វើអោយប៉ះពាល់ជាអវិជ្ជមានកម្រិតណាដល់ផែនការអនុវត្តការងាររបស់អ្នក? | a. មិនមានផលប៉ះពាល់ទេ<br>b. ប៉ះពាល់តិចតួច<br>c. ប៉ះពាល់មធ្យម<br>d. ប៉ះពាល់បង្គួរ<br>e. ប៉ះពាល់ខ្លាំង |
| 2.2. តើអ្នកបានធ្វើអ្វីខ្លះ ក្នុងការឆ្លើយតបទៅនឹងបញ្ហានេះ ក៏ដូចជាជួយដល់ក្រុមគោលដៅរបស់អ្នក? | ……………………………………………………………………<br>……………… |
| 2.3. តើមានផលលំបាក/បញ្ហាប្រឈមអ្វីខ្លះដែលបានជួប្រទះក្នុការអនុវត្តការងាររបស់អ្នក? | ………………………………………………………………………<br>…………… |

| 3. សកម្មភាព និងផលប៉ះពាល់សម្រាប់កម្រិតស្ថាប័ន | |
|---|---|
| 3.1. តើបញ្ហាប្រឈមដែលស្ថាប័នអ្នកកំពុងជួបប្រទះមានវិសាលភាពកម្រិតណា? | a. មិនមានបញ្ហាប្រឈម និងអាចធ្វើតាមផែនការ<br>b. មិនអាចបំពេញការងារមួយចំនួនតាមផែនការ<br>c. មិនអាចបំពេញការងារមួយចំនួនមធ្យមតាមផែនការ<br>d. មិនអាចបំពេញការងារមួយចំនួនធំតាមផែនការ<br>e. មិនអាចបំពេញសកម្មភាពទាំងអស់តាមផែនការ |
| 3.2. តើមានវិធានការអ្វីខ្លះដែលអ្នកបានលើកឡើង ឬគិតគូរត្រៀមឆ្លើយតប ជំងឺកូវីដ១៩? *(ចម្លើយលើសពីមួយ)* | a. លើកកម្ពស់សុខភាព និងសុវត្ថិភាពសម្រាប់បុគ្គលិក<br>b. ផ្តល់អោយបុគ្គលិកបត់បែនរបៀបធ្វើការ *(ធ្វើតាមផ្ទះ)*<br>c. បង្កើតយន្តការទំនាក់ទំនងដល់បុគ្គលិក និង អ្នកទទួលផល<br>d. រក្សាទំនាក់ទំនងជាមួយម្ចាស់ជំនួយអំពីការផ្លូផែនការ<br>e. សំណើដល់ម្ចាស់ជំនួយ និងដៃគូជំនួយសម្រាប់ការពន្យាពេល ចំណាយ<br>f. ផ្សេងៗ*(សូមបញ្ជាក់រាល់ចម្លើយផ្សេងៗ)*៖ ____ |
| 3.3. ប្រសិនបើជំងឺ កូវីដ១៩ នៅតែបន្តលើសពី៣ ខែ ឬយូរជាងនេះ តើអង្គការអ្នកនឹងឆ្លើយតបយ៉ាងណាក្នុងអំឡុងពេល និងក្រោយពេលមានបញ្ហា? | ……………………………………………………………………<br>……………………………………………………………………<br>……… |
| 3.4. ប្រសិនបើជំងឺនៅតែបន្តផ្ទុះ រហូតដល់បីខែឬយូរជាងនេះ តើអង្គការអ្នកនឹងគិតគូយ៉ាងណាពីគណនេយ្យភាព សម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងសហគមន៍ *(ដូចជា ប្រាក់ខែ និង អត្ថប្រយោជន៍ របៀបធ្វើការជាដើម……)?* | ……………………………………………………………………<br>……………………………………………………………………<br>……………… |

| 4. **យោបល់ និងសំណូមពរផ្សេងៗ** |
| --- |
| 4.1. សម្រាប់អង្គការ គ ស គ……………………………………………………………………………………………………………………<br>………………………………………………………………………………………………………………………………<br>…… |
| 4.2. សម្រាប់ដៃគូម្ចាស់ជំនួយ ………………………………………………………………………………………………………<br>………………………………………………………………………………… |
| 4.3. សម្រាប់រដ្ឋាភិបាល………………………………………………………………………………………………………………<br>……………………………………………………………………………………… |

<u>**សូមអរគុណ!**</u>

# របាយការណ៍ស្ទង់មតិ

# សកម្មភាព និងផលប៉ះពាល់របស់អង្គការសង្គមស៊ីវិល

# ពីជំងឺរាតត្បាត "កូវីដ១៩"

ខែមេសា ឆ្នាំ២០២០

# មាតិកា

ពាក្យកាត់ ..... 3
សេចក្តីថ្លែងអំណរគុណ ..... 4
បុព្វកថា ..... 5
ខ្លឹមសារសង្ខេប ..... 6

**១. សេចក្តីផ្តើម** ..... 8
**២. គោលបំណងនៃការស្រាវជ្រាវ** ..... 8
**៣. វិធីសាស្ត្រស្រាវជ្រាវ** ..... 9
**៤. លទ្ធផលសំខាន់ៗពីការស្ទង់មតិ** ..... 10
**៤.១. សារតារបស់អ្នកឆ្លើយតប** ..... 10
៤.១.១. ប្រភេទអង្គការ និងឋានានុក្រមរបស់អ្នកឆ្លើយតប ..... 10
៤.១.២. ប្រភេទអ្នកទទួលផល ..... 11
៤.១.៣. តាមវិស័យការងារ ..... 12
៤.១.៤. តំបន់គោលដៅនៃកម្មវិធី ..... 12
**៤.២. សកម្មភាព និងផលប៉ះពាល់កម្រិតសកម្មភាព និងកម្មវិធី** ..... 13
៤.២.១. កម្រិតនៃផលប៉ះពាល់លើកម្មវិធី និងសកម្មភាព ..... 13
៤.២.២. បញ្ហាប្រឈមលើកម្មវិធី និងកម្រិតសកម្មភាព ..... 14
៤.២.៣. សកម្មភាពឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាជំនួយទៅកាន់អ្នកទទួលផល ..... 16
**៤.៣. សកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន** ..... 17
៤.៣.១. បញ្ហាប្រឈមមុខនៃកម្រិតស្ថាប័ន ..... 17
៤.៣.២. សកម្មភាពអង្គការ និងការពិចារណាយ៉ាងហ្មត់ចត់ ដើម្បីឆ្លើយតបជំងឺកូវីដ១៩ ..... 18
៤.៣.៣.សកម្មភាពឆ្លើយតប ប្រសិនបើការឆ្លងនៅតែបន្តរហូតដល់រយៈពេលខែ ឬយូរជាងនេះ..19
៤.៣.៤. គណនេយ្យភាពសម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងអ្នកទទួលផល ប្រសិនបើបន្តការឆ្លង 22
**៥. សំណូមពរ និងយោបល់ផ្សេងៗ** ..... 25
**៥.១. សម្រាប់ អង្គការ ត.ស.ក** ..... 25
**៥.២. សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ** ..... 28
**៥.៣. សម្រាប់រាជរដ្ឋាភិបាល** ..... 29

ឧបសម្ព័ន្ធ១: កម្រងសំណួរសម្រាប់ស្ទង់មតិ ..... 31

# ពាក្យកាត់

| | |
|---|---|
| ស៊ី.ប៊ី.អូ (CBOs) | អង្គការសហគមន៍មូលដ្ឋាន |
| ស៊ី.ស៊ី.ស៊ី (CCC) | អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) |
| ស៊ី.ឌី.ស៊ី (CDC) | មជ្ឈមណ្ឌលសម្រាប់គ្រប់គ្រង និងការពារជំងឺឆ្លង |
| ស៊ី.អ៊ឹម.ឌី (CMD) | ទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិកភាព |
| ស៊ី.អេស.អូ (CSOs) | អង្គការសង្គមស៊ីវិល |
| កូវីដ១៩ (COVID-19) | វីរុសឆ្លងកូរ៉ូណា (កូវីដ១៩) |
| ឌី.អ័រ.អ័រ (DRR) | ការកាត់បន្ថយគ្រោះមហន្តរាយ និងហានិភ័យ |
| អែហ្វ.អេន.ជី.អូ (FNGOs) | អង្គការមិនមែនរដ្ឋាភិបាលបរទេស |
| ជី.ឌី.ធី (GDT) | អគ្គនាយកដ្ឋានពន្ធដារ |
| អាយ.អ៊ី.ស៊ី (IEC) | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| អេល.អិន.ជី.អូ (LNGOs) | អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក |
| អឹម.អែហ្វ.អាយ (MFI) | វិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ |
| អឹម.អូ.អេច្ឆ (MoH) | ក្រសួងសុខាភិបាល |
| អិន/អេ (N/A) | មិនមានចម្លើយ |
| អិន.អ័រ.អឹម (NRM) | ការគ្រប់គ្រងធនធានធម្មជាតិ |
| អិន.អេស.អេស.អេហ្វ | មូលនិធិជាតិ សន្តិសុខសង្គម |
| ដាប់បិលយូ.អេច្ឆ.អូ (WHO) | អង្គការសុខភាពពិភពលោក |

# សេចក្តីថ្លែងអំណរគុណ

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បី កម្ពុជា (គ.ស.ក) តាមរយៈផ្នែកទំនាក់ទំនង និង អភិវឌ្ឍន៍សមាជិកភាព (ស៊ី.អឹម.ឌី) ដែលជាអ្នកសម្របសម្រួលលើកិច្ចការយ៉ាងជិតស្និតជាមួយនឹង សហការីផ្សេងទៀតក្នុងស្ថាប័ន សូមសម្តែងនូវសេចក្តីអំណរគុណ ដោយស្មោះត្រង់ទៅកាន់ ទាំង សមាជិក និងមិនសមាជិក របស់ អង្គការ គ.ស.ក បណ្តាញអង្គការតាមបណ្តាខេត្ត អង្គការសហគមន៍ មូលដ្ឋាន និងដៃគូពាក់ព័ន្ធនៃអង្គការសង្គមស៊ីវិលទាំងអស់ សម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមបំពេញក្នុងទម្រង់សំណួរស្ទង់មតិនេះ។ អរគុណផងដែរចំពោះប្រធានគ្រប់គ្រង និង បុគ្គលិក តាមផ្នែកនីមួយៗរបស់ អង្គការ គ.ស.ក សម្រាប់ការផ្តល់ធាតុចូល ក៏ដូចជា ការប្រមូលនូវ ទិន្នន័យពីអង្គការដៃគូ។ ជាងនេះ សូមអំណរគុណជាខ្លាំង ចំពោះលោក សឿង សារឿន ជានាយក ប្រតិបត្តិនៃអង្គការ គ.ស.ក ដែលជាអ្នកផ្តួចផ្តើមគំនិតលើការស្ទង់មតិ ជាមួយនឹងការផ្តល់ប្រឹក្សា យោបល់ដ៏មានតម្លៃ ទៅលើមាតិកានៃការសិក្សា ក៏ដូចជានៅក្នុងរបាយការណ៍នេះ។ សូមអរគុណ ចំពោះលោក ជេន សុជឿន នៅក្នុងការរៀបចំរបាយការណ៍ ហើយក៏អរគុណផងដែរចំពោះ អ្នកស្រី លុយ ធារី ក្នុងការគាំទ្រសម្រាប់ការចងក្រងបង្ហាញនៃការវិភាគលើទម្រង់សំណួរបើកមួយចំនួន ក៏ដូចជា ពិនិត្យឡើងវិញលើកម្រងសំណួរទាំងនេះ ហើយក៏ពេញចិត្តជាការខ្លាំងសម្រាប់ការផ្តល់មតិយោបល់ពី មិត្តរួមការងារ និងសមាជិករបស់យើងទាំងអស់ទៅលើលទ្ធផលបឋម។

ជាចុងក្រោយ សូមថ្លែងអរគុណដល់អ្នកចូលរួមក្នុងការស្ទង់មតិនេះ ហើយយើងរំពឹងថា របាយ ការណ៍នេះ នឹងក្លាយទៅជាឯកសារគន្លឹះ សម្រាប់សមាជិក និងដៃគូដទៃទៀតរបស់ អង្គការ គ.ស.ក ដើម្បីងាយស្រួល និងបានជ្រួតជ្រាបពីស្ថានភាពនាពេលថ្មីៗនេះ ពីផលប៉ះពាល់របស់ជំងឺកូវីដ១៩ ទៅ លើកម្មវិធី អង្គការ និងការឆ្លើយតបក៏ដូចជាត្រៀមរបស់សង្គមស៊ីវិលពាក់ព័ន្ធ។

*អរគុណលោក យ៉ងយ៉ាង ចន្ទ្រសីហា សម្រាប់ការសម្រួលរបាយការណ៍ជាភាសាខ្មែរ*

## បុព្វកថា

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាព បានផ្តួចផ្តើមសម្រង់ស្ទង់មតិនេះឡើង ក្នុងគោលបំណងស្វែងយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើអង្គការសង្គមស៊ីវិល ក៏ដូចជាស្វះស្វែងរកសំណូមពរឆ្លើយតបទៅនឹងពីផលប៉ះពាល់ផ្សេងៗ នាពេលថ្មីៗនេះ សម្រាប់កម្មវិធី និងស្ថាប័ន អង្គការសង្គមស៊ីវិល និងក្រុមអ្នកទទួលផល។ ការសម្រង់ស្ទង់មតិឆាប់នេះត្រូវបានប្រមូលជាទិន្នន័យកំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩ នៅចុងខែមីនា រហូតដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ ដើម្បីវាយតម្លៃផលប៉ះពាល់ និងទទួលធាតុចូល ពីភាគីពាក់ព័ន្ធផ្សេងៗ ដែលធ្វើការទាក់ទងជាមួយនឹងអង្គការសង្គមស៊ីវិល។ លទ្ធផលចេញពីការសិក្សានេះឆ្លុះបញ្ចាំងពីស្ថានភាព និងសកម្មភាពកម្រិតកម្មវិធី ក៏ដូចជាស្ថាប័ន។ លើសពីនេះទៅទៀត សំណូមពរ និងការផ្តល់មតិយោបល់ផ្សេងៗ ត្រូវដាក់រួមបញ្ចូលគ្នា ក្នុងការចូលរួមដោះស្រាយ ឬលើកឡើងពីបញ្ហាប្រឈមទៅកាន់ភាគីពាក់ព័ន្ធផ្សេងៗ ដែលមានជាពិសេសទៅកាន់អង្គការ គ.ស.ក ដៃគូអភិវឌ្ឍន៍/ដៃគូមូលនិធិ និងរាជរដ្ឋាភិបាល។

លទ្ធផលនេះគឺពិតជាមានអត្ថប្រយោជន៍ ក្នុងការផ្តល់ព័ត៌មានទៅកាន់រាល់ភាគីពាក់ព័ន្ធនូវអ្វីដែលអង្គការសង្គមស៊ីវិលកំពុងតែធ្វើ និងកំពុងពិចារណា ក៏ដូចជាការលើកឡើងនូវការផ្តល់យោបល់ផ្សេងៗ ក្នុងការឆ្លើយតបទៅការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ ដែលបានសាយភាយពាសពេញពិភពលោក។ យើងខ្ញុំសង្ឃឹមថា លទ្ធផលនេះ អាចផ្តល់ដល់យើងទាំងអស់គ្នា នូវអ្វីដែលយើងបានចូលរួមធ្វើក្នុងការដោះស្រាយ ក៏ដូចជាអ្វីដែលយើងទាំងអស់គ្នា គួរខិតខំបន្តទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលថ្មីៗនេះ និងយុទ្ធសាស្ត្រដោះស្រាយសម្រាប់ពេលអនាគត។

**សឿង សារឿន**

នាយកប្រតិបត្តិ នៃអង្គការ គ.ស.ក

ខែមេសា ឆ្នាំ២០២០

## ខ្លឹមសារសង្ខេប

ការស្ទង់មតិនេះត្រូវបានធ្វើឡើងដោយអង្គការគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា (គ.ស.ក) ក្នុងកំឡុងពេលការរីកសាយភាយនៃជំងឺកូវីដ១៩ នៅទូទាំងពិភពលោកក៏ដូចជា ក្នុងប្រទេសកម្ពុជាផងដែរ ក្នុងគោលបំណងដើម្បីស្វែងយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើកម្មវិធីសកម្មភាពរបស់អង្គការសង្គមស៊ីវិល ក៏ដូចជាស្វែងរកសំណូមពរឆ្លើយតប លើផលប៉ះពាល់នាពេលថ្មីៗនេះ។ ទម្រង់ស្ទង់មតិនេះត្រូវបានចែកចាយទៅកាន់សមាជិករបស់អង្គការ គ.ស.ក រួមទាំងបណ្ដាញអង្គការមិនមែនរដ្ឋាភិបាលតាមបណ្ដាខេត្ត អង្គការសហគមន៍មូលដ្ឋាន និងដៃគូពាក់ព័ន្ធដទៃទៀត ដែលបានកំពុងធ្វើការទាក់ទងជាមួយនឹងអង្គការសង្គមស៊ីវិល។ ជាលទ្ធផល មានអ្នកឆ្លើយតបចំនួន ១៥៤ ដែលកំពុងធ្វើការលើវិស័យចម្រុះផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា។

ជាលទ្ធផលនៃស្ទង់មតិនេះ បានចង្អុលបង្ហាញពីផលប៉ះពាល់យ៉ាងច្រើន លើការងារ និងគម្រោងកម្មវិធី ព្រមទាំងអង្គការ ដែលអាចប្រៀបធៀបមានលក្ខណៈស្រដៀងគ្នា។ សម្រាប់កម្មវិធី ស្ទើរជិតពាក់កណ្ដាលនៃអ្នកឆ្លើយតប បានធ្វើចំណាត់ថ្នាក់ក្នុងចំណោមផលប៉ះពាល់អាក្រក់ក្នុងកម្រិតខ្ពស់ ៤៧ ភាគរយ/៧២នៃអ្នកឆ្លើយតប ពីជំងឺកូវីដ១៩ ខណៈដែលក្នុងកម្រិតស្ថាប័នក៏មានផលប៉ះពាល់អាក្រក់ យ៉ាងតិចបំផុត ៤៦ភាគរយ ដែលស្ថិតក្នុងកម្រិត មិនអាចធ្វើសកម្មភាពភាគច្រើនដូចការគ្រោងទុក។ មានគម្រូរួមមួយចំនួន នៃបញ្ហាប្រឈម គឺពាក់ព័ន្ធការពន្យាពេលនៃគម្រោងសកម្មភាព បញ្ហាប្រឈមរបស់បុគ្គលិក បញ្ហាកញ្ចប់ថវិកា/មូលនិធិ សម្ភារៈគាំទ្រពីការឆ្លើយតបបន្ទាន់ សម្ភារៈដើម្បីបម្រើកិច្ចការតាមប្រព័ន្ធអនឡាញ បញ្ហាបណ្ដាញប្រព័ន្ធអ៊ីធឺណែត ការខ្វះខាតព័ត៌មាន ការរឹតត្បឹតនៃការជួបជុំក្រុម/ការជួបប្រជុំ និងបញ្ហាផ្សេងៗទៀត។

ក្នុងការឆ្លើយតបទៅនឹងការរាតត្បាត ការដាក់ចេញនូវសកម្មភាពឆ្លើយតបមួយចំនួនត្រូវបានធ្វើឡើង និងគិតណាយ៉ាងយកចិត្តទុកដាក់ ដើម្បីអនុវត្ត ក្នុងចំណោមរាល់ប្រភេទចម្លើយពាក់ព័ន្ធផ្សេងៗគ្នារួមមាន៖ ជាមួយនឹងបុគ្គលិក ម្ចាស់ជំនួយ អ្នកទទួលផល និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្នុងចំណោមទាំងនោះមាន ៩៤% ទើបបានលើកកម្ពស់សុខមាលភាព និងការអនុវត្ត ដែលមានសុវត្ថិភាពសម្រាប់បុគ្គលិក។ ជាមួយអត្រាចំនួន ៨៨% បានរក្សាទំនាក់ទំនងជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ អំពីការកែប្រែផែនការសកម្មភាព និងមាន ៨៧% ដែលអនុញ្ញាតឱ្យបុគ្គលិកមានភាពបត់បែនទៅនឹងការរៀបចំការងាររបស់ខ្លួន (ឧទាហរណ៍៖ ធ្វើការពីផ្ទះ/ចម្ងាយ) និងការឆ្លើយតបសកម្មភាពជាច្រើនទៀតដើម្បីជួយអ្នកទទួលផលនៃកម្រិតកម្មវិធី។

បន្ថែមពីនេះទៅទៀត មានការបើកចំហានូវការផ្តល់យោបល់ និងសំណូមពរទៅកាន់ភាគីពាក់ព័ន្ធសំខាន់ផ្សេងៗ ទាំងនោះរួមមាន៖ ១) ចំពោះអង្គការ គ.ស.ក៖ ការចែករំលែកព័ត៌មាន ការគៀរគរធនធាន និងជំនួយឧបត្ថម្ភផ្សេងៗ ការជួយជាសម្ភារៈអនាម័យ និងសម្ភារៈសម្រាប់ការអប់រំផ្សព្វផ្សាយផ្សេងៗ ការសិក្សារៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព ការអនុវត្តច្បាប់និងពន្ធដារ ការសិក្សាស្រាវជ្រាវនិងការវាយតម្លៃផលប៉ះពាល់ យន្តការការងារជាមួយនឹងភាគីពាក់ព័ន្ធកំឡុងពេល និងក្រោយនៃជំងឺកូវីដ១៩ ការកសាងបណ្តាញ និងកិច្ចសហការ ។ល។ ២) ចំពោះម្ចាស់ជំនួយ៖ ការប្រឹក្សាពិគ្រោះយោបល់ជាមួយម្ចាស់ជំនួយ ដើម្បីស្វែងរកជម្រើស/ដំណោះស្រាយទៅលើរបៀបអនុវត្តគម្រោង និងជួយគាំទ្រក្រុមគោលដៅ ជួយបង្កើនការគាំទ្រហិរញ្ញវត្ថុចំពោះប្រតិបត្តិការគម្រោង និងសហគមន៍រក្សាការគាំពារអត្ថប្រយោជន៍បុគ្គលិកនៅក្នុងរយៈពេលនៃការរាតត្បាតនេះ ផ្តល់នូវជំនួយមូលនិធិទៅលើការសង្គ្រោះបន្ទាន់ អនុញ្ញាតឱ្យមានការពន្យារិសាលភាពគម្រោង និងការជួយកែសម្រួលនៃអន្តរាគមន៍។ល។ ៣) ចំពោះរដ្ឋាភិបាល៖ ផ្តល់ជូននូវសកម្មភាពដ៏សមរម្យ និងគោលការណ៍ណែនាំច្បាស់លាស់ ផ្តល់នូវការជួយឧបត្ថម្ភចំណីអាហារទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ និងរងផលប៉ះពាល់ ជាពិសេសនោះអ្នកដែលនៅក្នុងតំបន់ដាច់ស្រយាល បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ធ្វើបច្ចុប្បន្នភាព និងចែករំលែកព័ត៌មានដែលគួរជឿទុកចិត្ត និងមានតម្លាភាពអំពីជំងឺកូវីដ១៩ ហើយនិងផលប៉ះពាល់របស់វា នៅក្នុងប្រទេសកម្ពុជា ជាដើម។

## ១. សេចក្តីផ្តើម

មកដល់ដើមឆ្នាំ២០២០ កិច្ចការងាររបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ទទួលរងនូវផលប៉ះពាល់ដោយសារវីរ៉ុសកូរូណា ឬជំងឺកូវីដ១៩ ដែលរីកសាយភាយយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក។ គិតមកដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ នៅក្នុងប្រទេសកម្ពុជា មានករណីឆ្លងជំងឺកូវីដ១៩ ចំនួន១២២ នាក់ ហើយនេះបង្កឱ្យមានក្តីព្រួយបារម្ភយ៉ាងខ្លាំង និងគួរឱ្យកត់សម្គាល់ក្នុងចំណោមសាធារណៈជន បើទោះបីចំនួនអ្នកជំងឺប្រហែលពាក់កណ្តាលទើបតែបានជាសះស្បើយពីការសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យក្តី។ ខណៈពេលឆ្លើយតបទៅនឹងវិធានការនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ជា ឬសេចក្តីណែនាំមួយចំនួន ដើម្បីការពារពីការរីករាលដាលឆ្លងនៃជំងឺនេះនៅទូទាំងប្រទេស។ វិធានការទាំងនោះរួមមាន ការបិទសាលារៀន បិទការជួបជុំនៅទីកន្លែងសាធារណៈ ទីកន្លែងកំសាន្ត ការគ្រប់គ្រងពលករអន្តោប្រវេសន្ត៍/ពលករចំណាកស្រុក ការប្រារព្ធកម្មវិធីសង្គម និងពិធីបុណ្យសាសនា ក៏ដូចជាលទ្ធភាពនៃការដាក់ប្រទេសនៅក្នុងភាពមានអាសន្ន ដូចដែលសេចក្តីព្រាងច្បាប់ទើបតែបានពិភាក្សារួចរាល់។ បញ្ហានេះតិច ឬច្រើនបានធ្វើឱ្យមានផលប៉ះពាល់ចំពោះ សកម្មភាព និងលទ្ធផលរបស់អង្គការសង្គមស៊ីវិលសម្រាប់ការអនុវត្តកម្មវិធី និងដំណើរការអង្គការ។

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ដែលជាអង្គការសមាជិកភាពដែលមានអាយុកាលវ័យចំណាស់ជាងគេមួយនេះ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការងារសម្របសម្រួល អភិបាលកិច្ច និងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ហើយបានផ្តួចផ្តើមការស្ទង់មតិនេះឡើង។ ក្នុងរបាយការណ៍នេះនឹងបង្ហាញជាពិសេសពីប្រវត្តិព័ត៌មានរបស់អ្នកផ្តល់ចម្លើយ សកម្មភាព និងផលប៉ះពាល់នូវកម្រិតកម្មវិធី និងកម្រិតស្ថាប័នទាំងរយៈពេលខ្លី ក៏ដូចជាវែង ព្រមទាំងផ្នែកចុងក្រោយ មានសំណើផ្សេងៗ សម្រាប់ដៃគូពាក់ព័ន្ធសំខាន់ៗ។ តាមការរំពឹងទុក លទ្ធផលនេះនឹងជាការជូនដំណឹងដ៏ល្អមួយ សម្រាប់អង្គការសង្គម ស៊ីវិល និងរាល់ដៃគូក្នុងការរៀបចំយុទ្ធសាស្ត្រ និងសកម្មភាពក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមថ្មីៗ និងដំណោះស្រាយផ្សេងៗជាមួយបញ្ហាទាំងនេះ។

## ២. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីស្វែយល់អំពីសកម្មភាព និងផលប៉ះពាល់ទៅលើការអនុវត្តការងាររបស់អង្គការសង្គមស៊ីវិលពីជំងឺកូវីដ១៩ ទៅលើកម្មវិធី ស្ថាប័ន និងក្រុមគោលដៅក៏ដូចជាស្វែងរកនូវមតិយោបល់ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមថ្មីៗ និងយុទ្ធសាស្ត្ររយៈពេលវែង។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅក្នុងភាពបន្ទាន់របស់អង្គការសង្គមស៊ីវិលកំឡុងពេលនៃការវាយប្រហារដោយជំងឺឆ្លងកូវីដ១៩។ កម្រងសំណួរត្រូវបានគ្រោងឡើងទាំងតាមសារអេឡិចត្រូនិច និងទម្រង់បំពេញអនឡាញ តាមរយៈទម្រង់ហ្គូហ្គល និងផ្ញើទៅកាន់ប្រព័ន្ធទំនាក់ទំនងដែលមានពីអង្គការ គ.ស.ក ដល់អ្នកដែលកំពុងធ្វើការទាក់ទងទៅនឹងការងារអង្គការសង្គមស៊ីវិល។ អ្នកទាំងនោះរួមមានសមាជិក និងមិនទាំងសមាជិករបស់ អង្គការ គ.ស.ក បណ្ដាញអង្គការសង្គមស៊ីវិលតាមបណ្ដាខេត្ត អង្គការសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត។ ក្រៅពីប្រព័ន្ធអេឡិចត្រូនិចអ៊ីម៉ែល តំណភ្ជាប់នៃការស្ទង់មតិនេះ ក៏ត្រូវបានផ្សព្វផ្សាយចែករំលែកទៅក្នុងគេហទំព័រហ្វេសប៊ុករបស់ អង្គការ គ.ស.ក ក៏ដូចជាប្រព័ន្ធសង្គមចែកចាយដទៃទៀតដូចជា ក្រុមតេឡេក្រាម ព្រមទាំងលើកទឹកចិត្តឱ្យដៃគូផ្សេងទៀត ក្នុងការចែករំលែកបន្តនៃសម្រង់ស្ទង់មតិនេះ ហើយមានការរំលឹកឡើងវិញតាមសារអេឡិចត្រូនិចក្នុងការជម្រុញលើកទឹកចិត្តអោយមានការចូលរួមផ្ដល់ចម្លើយរហូតដល់កាលបរិច្ឆេទបិទ។

ការប្រមូលទិន្នន័យគឺត្រូវបានបង្កើតឡើងកាលពីចុងខែមីនា រហូតដល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២០ ហើយជាលទ្ធផលមានការឆ្លើយតបចំនួន ១៥៩ ក្នុងការស្ទង់មតិនេះ។ ក្នុងចំណោមការឆ្លើយតបទាំងនោះមាន ១៩អង្គការ ដែលមានលើសពីមួយនាក់ចូលរួមនៅក្នុងការឆ្លើយតប។ សម្រាប់សម្រង់ស្ទង់មតិនេះ មានសំណួរមួយចំនួនត្រូវបានធ្វើឡើង ជាប្រភេទចម្លើយបើក ដើម្បីទទួលបាននូវការឆ្លើយតបចម្រុះផ្សេងៗគ្នា *(សូមមើលកម្រងសំណួរស្ទង់មតិនៅក្នុងឧបសម្ព័ន្ធ)*។ ជាចុងក្រោយ ទិន្នន័យដែលទទួលបាននេះត្រូវបានយកមកវិភាគ ជាមួយនឹងស្ថិតិបរិយាយរៀបរាប់ (descriptive statistic) និងតម្រៀបកូដចម្លើយបើកទាំងនោះតាមប្រភេទ ព្រមទាំងធ្វើការវាស់វែងនូវចំនួនចម្លើយទាំងនោះតាមបែបបរិមាណ ដើម្បីវាយតម្លៃពីទំហំ ថាតើការឆ្លើយតបណាខ្លះ ដែលមានចំនួនតិច និងច្រើន។ម្យ៉ាងវិញទៀតរាល់ការចូលរួមជាមតិយោបល់ និងសំណូមពរ ក៏ត្រូវបានចងក្រងជារួមនៅផ្នែកចុងក្រោយទៅក្នុងរបាយការណ៍នេះផងដែរ។

# ៤. លទ្ធផលសំខាន់ៗពីការស្ទង់មតិ

## ៤.១. សារតារបស់អ្នកឆ្លើយតប

### ៤.១.១. ប្រភេទអង្គការ និងឋានានុក្រមរបស់អ្នកឆ្លើយតប

ប្រវត្តិសារតារបស់អ្នកឆ្លើយតបត្រូវបានពិភាក្សានៅក្នុងរបាយការណ៍នេះ ផ្តោតទៅលើប្រភេទអង្គការ ឋានានុក្រម (តួនាទី) របស់អ្នកឆ្លើយតប ប្រភេទអ្នកទទួលផលផ្ទាល់ ដែលអង្គការកំពុងធ្វើការ និងតំបន់គោលដៅ ដែលកម្មវិធីកំពុងដំណើរការ។

តាមរយៈសម្រង់ស្ទង់មតិមានការចូលរួមពីអ្នកឆ្លើយតបចំនួន ១៥៤ ដែលក្នុងចំណោមអ្នកទាំងនោះមានអង្គការចំនួន១៤ ដែលមានអ្នកឆ្លើយតបផ្សេងគ្នាក្នុងមួយអង្គការ ដោយសារតែការទទួលបាននូវការចែករំលែកទម្រង់នៃការស្ទង់មតិផ្សេងៗគ្នា។ ក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ មានច្រើនតំណាងអោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក រហូតដល់ ៦២ភាគរយ ខណៈដែល តំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេស ៣៤ ភាគរយ តំណាងអង្គការសហគមន៍មូលដ្ឋាន ៣ ភាគរយ និងមានតែ១ភាគរយប៉ុណ្ណោះ មកពីផ្នែកសិក្សាឬសាកលវិទ្យាល័យ និងអ្នកជំនាញ (freelance consultant) ដែលធ្វើការទាក់ទងនឹងកិច្ចការរបស់អង្គការសង្គមស៊ីវិល។

*រូប ៤.១ ប្រភេទអង្គការ និង រូប ៤.២. តួនាទីរបស់អ្នកឆ្លើយតប*



ម្យ៉ាងវិញទៀត អ្នកឆ្លើយតបដែលមានមុខតំណែងជាថ្នាក់ដឹកនាំ ឬប្រធានអង្គការ (៧៣%) ដែលមានអត្រាភាគរយខ្ពស់ក្នុងចំណោមនៃអ្នកឆ្លើយតបទាំងអស់ និងបន្ទាប់មកទៀត អ្នកធ្វើការជាអ្នកកម្មវិធី (១៥%) និងមានតែ ៦% ប៉ុណ្ណោះ ដែលជាបុគ្គលិកផ្នែកប្រតិបត្តិ។ លទ្ធផលនេះគឺជាការផ្តល់នូវទឡ្ហីករណ៍គន្លឹះមួយអំពីទិន្នន័យពាក់ព័ន្ធ ដែលគួរឱ្យជឿទុកចិត្ត សម្រាប់តំណាងជាលក្ខណៈអង្គភាពក្នុងការឆ្លុះបញ្ចាំងតាមស្ថាប័ននីមួយៗ ដែលលើកឡើងនៅក្នុងការស្ទង់មតិនេះ។

### ៤.១.២. ប្រភេទអ្នកទទួលផល

មានប្រភេទផ្សេងៗគ្នានៃអ្នកទទួលផលក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ ដែលស្ថិតក្នុងប្រភេទនៃក្រុមសង្គមផ្សេងៗគ្នាដូចជា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងក្រុមអង្គការសហគមន៍មូលដ្ឋាន ក្រុមយុវជន ក្រុមដែលមានវ័យចំណាស់ ក្រុមស្ត្រី អ្នកក្រីក្រ សិស្ស/និស្សិត និងគ្រូបង្រៀន ជាដើម។ ក្នុងនោះយុវជនមាន (១០២) និងកុមារ(៩៥) គឺមានចំនួនប្រហែលគ្នាច្រើនជាងគេ នៅក្នុងចំណោមក្រុមអ្នកទទួលផល។ ហើយបន្តបន្ទាប់មានក្រុមជនពិការភាព (៤៦) និង មនុស្សចាស់ (១២)។ ចំណែកឯប្រភេទក្រុមអ្នកទទួលផលដទៃទៀតគឺស្ថិតក្នុងទំហំតូច រាយប៉ាយក្នុងរង្វង់នៃទិន្នន័យនេះ។

*រូប ៤.៣. ប្រភេទនៃអ្នកទទួលផល*



### ៤.១.៣. តាមវិស័យការងារ

យ៉ាងហោចណាស់មានចំនួន ៣៥ វិស័យការងារត្រូវបានបែងចែកចេញពីចម្លើយនៃសំណួរបើកនេះ។ លទ្ធផល បង្ហាញឱ្យឃើញពីអង្គការរបស់អ្នកឆ្លើយតប ដែលកំពុងធ្វើការលើវិស័យផ្សេងៗគ្នា ហើយប្រេកង់នៃវិស័យចម្បងនោះគឺ វិស័យអប់រំ (៥៣) និងសុខភាព (៣៦) បន្ទាប់មកទៀតផ្តោតលើ អាហាររូបត្ថម្ភ និងអនាម័យ (២៦) កសិកម្ម (២០) ជីវភាពរស់នៅប្រចាំថ្ងៃ (១៧) ការអភិវឌ្ឍសហគមន៍ (១៥) ការកាត់បន្ថយគ្រោះមហន្តរាយ និងហានិភ័យ (១១) ការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លី (១៦)។ ចំពោះវិស័យដទៃទៀតគឺជាចំនួនដ៏តូចនៅក្នុងរង្វង់ទិន្នន័យ។

*រូប ៤.៤. វិស័យនៃការងារអង្គការ*




### ៤.១.៤. តំបន់គោលដៅនៃកម្មវិធី

ក្នុងចំណោមអ្នកឆ្លើយតបទាំងនោះ មានកម្មវិធី/គម្រោងដែលកំពុងអនុវត្តការងារនៅទូទាំងខេត្តក្រុងនៃប្រទេសកម្ពុជា។ ដោយឡែកភ្នំពេញ គឺជារាជធានីរបស់ប្រទេសកម្ពុជា ដែលមានការិយាល័យកណ្តាលនៃអង្គការសង្គមស៊ីវិលជាច្រើន ដែលធ្វើអោយទីតាំងសម្រាប់ចំនួនកម្មវិធីគោលដៅចម្បង មានចំនួនច្រើនជាងគេ (៦៨) និងចំនួនបន្តបន្ទាប់មកទៀត ដែលមានតួរលេខខ្ពស់ផងដែរនោះ ស្ថិតនៅ

ក្នុងខេត្តបាត់ដំបង (៥៥) និងខេត្តសៀមរាប (៥០)[1]។ ចំណែកឯចំនួននៃទីតាំងគោលដៅតិចតួចនោះស្ថិតនៅក្នុងតំបន់តូច និងដែលមានអត្រាដង់ស៊ីតេប្រជាជនទាបនោះគឺខេត្តកែប ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ ជាដើម។

*រូប ៤.៥. ទីតាំងអនុវត្តគម្រោង*




## ៤.២. សកម្មភាព និងផលប៉ះពាល់កម្រិតសកម្មភាព និងកម្មវិធី

### ៤.២.១. កម្រិតនៃផលប៉ះពាល់លើកម្មវិធី និងសកម្មភាព

យោងតាមរូប ៤.៣. បានបង្ហាញពីកម្រិតនៃបញ្ហាប្រឈមទៅលើកម្មវិធី និងសកម្មភាព ហើយស្ទើរតែទាំងអស់បានរងផលប៉ះពាល់ជាអវិជ្ជមានដោយសារជំងឺកូវីដ១៩ សម្រាប់ការអនុវត្តកម្មវិធីដែលឈានទៅដល់ការពន្យាពេល ឬក៏មិនអាចធ្វើតាមការគ្រោងទុករបស់ខ្លួនបាន ហើយមានតែ ១ ភាគរយប៉ុណ្ណោះ (២អង្គការ) ស្ថិតក្នុងខេត្តក្រចេះ និងខេត្តកោះកុង ដែលបាននឹងកំពុងធ្វើការ ភាគច្រើននៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ព្រៃឈើ ដែលអាចអនុវត្តការងារបានតាមគម្រោងសកម្មភាព និងផែនការរបស់ខ្លួន។

---

[1] លទ្ធផលនេះស្របគ្នាផងដែរជាមួយនឹងការសិក្សាស្រាវជ្រាវពីការរួមចំណែករបស់អង្គការសង្គមស៊ីវិល តាមរយៈនៃការអង្កេត និងជំរឿនអង្គការសង្គមស៊ីវិលកាលពីឆ្នាំ២០១២ ក្នុងតំណភ្ជាប់នេះ https://www.ccc-cambodia.org/en/download?file_id=804&action=view&view_file_id=fccc489b12587930d92aad790eb0a9f0e0740534

នៅក្នុងការធ្វើចំណាត់ថ្នាក់ពីកម្រិតនៃផលប៉ះពាល់ចាប់ពី ១ (មិនមានផលប៉ះពាល់ទាំងអស់) ដល់៥ (មានផលប៉ះពាល់ធ្ងន់ធ្ងរ)។ ស្ទើរជិតពាក់កណ្ដាលនៃអ្នកឆ្លើយតប បានឱ្យចំណាត់ថ្នាក់ពីផលប៉ះពាល់កម្រិតខ្ពស់ ឬកម្រិត៥ (៤៧%/៧២ អ្នកឆ្លើយតប) ពីជំងឺកូវីដ១៩ និងបន្ទាប់ទៀតដោយលើសពីមួយភាគបីស្ថិតក្នុងផលប៉ះពាល់កម្រិតមធ្យម (កម្រិតកណ្ដាល) ឬកម្រិត ៤ (៣៧%)។

*រូប ៤.៦. ផលប៉ះពាល់លើគម្រោងសកម្មភាព និងផែនការ*




### ៤.២.២. បញ្ហាប្រឈមលើកម្មវិធី និងកម្រិតសកម្មភាព

ទម្រង់នៃបញ្ហាប្រឈមមួយចំនួនជារួមគឺពាក់ព័ន្ធនឹងការពន្យាពេលនៃគម្រោង ពីការដែលមិនអាចធ្វើសកម្មភាពតាមផែនការគ្រោងទុក បញ្ហាបុគ្គលិក បញ្ហាមូលនិធិ ជំនួយសម្ភារៈផ្សេងៗសម្រាប់ការឆ្លើយតបបន្ទាន់ សម្ភារដើម្បីបម្រើការងារតាមប្រព័ន្ធអនឡាញ ការតភ្ជាប់បណ្ដាញអ៊ីធឺណែត ការខ្វះខាតព័ត៌មាន ការរឹតបន្តឹងការធ្វើដំណើរ ការប្រមូលផ្តុំ និងការជួបប្រជុំ។

ក្នុងចំណោមនោះ បញ្ហាប្រឈមដែលមានប្រេកង់ខ្ពស់ជាងគេ គឺការដែលមិនអាចធ្វើសកម្មភាពតាមផែនការ ដែលនាំអោយមានការពន្យាពេល។ បន្ទាប់មកគឺមានភាពរាំងស្ទះបញ្ហាមូលនិធិ (ថវិកា) ក៏ដូចជាមិនអាចរៀបចំការជួបជុំខ្នាតធំ និងមានការចូលរួមពីសំណាក់អ្នកទទួលផលដោយសារតែការរឹតត្បឹត និងយោងសេចក្តីណែនាំពីសុវត្ថិភាព។

*តារាង៤.១ បញ្ហាប្រឈមលម្អិតលើការងារកម្រិតកម្មវិធី*

| បញ្ហាប្រឈមសម្រាប់កម្រិតកម្មវិធី | ប្រេកង់ |
|---|---|
| មិនអាចអនុវត្តសកម្មភាព និងពន្យាពេលគម្រោង | ៥៩ |
| មិនអនុញ្ញាតសម្រាប់ប្រជុំក្រុម ពីសំណាក់អាជ្ញាធរ ស្របតាមការឆ្លើយតបទៅនឹងសេចក្តីណែនាំពីសុវត្ថិភាពរបស់ក្រសួងសុខាភិបាល | ១៩ |
| សហគមន៍មានការភ័យខ្លាច និងមិនហ៊ានចូលរួមនៅក្នុងសកម្មភាពកម្មវិធី | ១០ |
| ហានិភ័យខ្ពស់ និងបញ្ហាប្រឈមសម្រាប់បុគ្គលិក | ៩ |
| ការបិទសាលារៀន លំបាកធ្វើការងារក៏ដូចជាការឆ្លើយតបការគាំទ្រតាមតម្រូវការផ្សេងៗ | ៨ |
| កាត់បន្ថយមូលនិធិជំនួយបណ្តាយមកពីសហគមន៍(ប្រទេស) ម្ចាស់ជំនួយ មានផលប៉ះពាល់ដូចគ្នា | ៦ |
| ធ្វើការពីផ្ទះ និងភាពលំបាកចូលទៅក្នុងកន្លែងសហគមន៍ផ្ទាល់ | ៦ |
| ការរឹតត្បិតការធ្វើដំណើរ និងកំណត់លទ្ធភាពចូលទៅក្នុងសហគមន៍ | ៦ |
| មិនទាន់មានភាពបន្សាំជាមួយនឹងការធ្វើការងារតាមប្រព័ន្ធអនឡាញ | ៥ |
| ខ្វះខាតមូលនិធិជំនួយ (ថវិកា) | ៤ |
| សម្ភារអនាម័យនៅមានកម្រិត | ៣ |
| ខ្វះខាតសម្ភារៈដើម្បីបម្រើការងារតាមប្រព័ន្ធអនឡាញ និងសំណើគាំទ្រផ្សេងៗ | ៣ |
| បុគ្គលិកមួយចំនួនមិនអាចធ្វើការពីផ្ទះ ឧទាហរហ៍អ្នកបើកបរ | ២ |
| មិនអាចចំណាយមូលនិធិតាមការគ្រោងទុក/គម្រោង | ២ |
| ផលិតភាព និងគុណភាពនៃការងារដែលធ្វើការពីផ្ទះនៅមានកម្រិត | ២ |
| ការភ័យខ្លាចនៃការរីកសាយភាយក្នុងចំណោមសហគមន៍ និងភាគីពាក់ព័ន្ធ | ២ |
| បញ្ហាភ្ជាប់បណ្តាញប្រព័ន្ធអ៊ីធឺណែត | ២ |
| ពិបាកទំនាក់ទំនង និងទទួលបានព័ត៌មាន | ២ |
| មិនអាចបង្កើតប្រាក់ចំណូលចេញពីកម្មវិធី | ២ |
| ខ្វះខាតអ្នកជំនាញ និងការចូលរួមពីសំណាក់អាជ្ញាធរ | ២ |

| | |
|---|---|
| ភាពយឺតយ៉ាវនៃការផ្តល់មូលនិធិពីម្ចាស់ជំនួយ | ១ |
| ម្ចាស់ជំនួសមិនអនុញ្ញាតឱ្យមានការផ្លាស់ប្តូរ ឬបង្វិលនៃថវិកា | ១ |
| អ្នកផ្គត់ផ្គង់ សេវាកម្ម និងភាពជាដៃគូជាមួយនឹងអ្នកពាក់ព័ន្ធនៅមានកម្រិត | ១ |
| មិនមានព័ត៌មានច្បាស់លាស់ពីរដ្ឋាភិបាលអំពីគម្រោងការបង្ខាំងមិនឱ្យចេញចូល | ១ |
| ក្រុមអ្នកស្ម័គ្រចិត្តពេលមានភាពបន្ទាន់មួយចំនួនតូច ធ្វើការបន្ថែមម៉ោងនិងបន្ថែមកិច្ចការដើម្បីជួយផ្តល់តាមតម្រូវការចាំបាច់ជាមូលដ្ឋានទៅកាន់ក្រុមគ្រួសារដែលឆ្លងជំងឺ | ១ |
| មិនអាចទៅមើលអ្នកជំងឺតាមរយៈនៃការអនុវត្តការងារពីចម្ងាយ | ១ |
| ភាពមិនប្រាកដនៃផែនការសម្រាប់ជម្រើសនៃការរៀបចំភស្តុភាផ្សេងៗ និងការចំណាយដែលមានតម្លៃខ្ពស់ | ១ |
| មិនមានចម្លើយ | ៣ |

### ៤.២.៣. សកម្មភាពឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាជំនួយទៅកាន់អ្នកទទួលផល

ក្នុងផ្នែកនេះ ស្វែងយល់អំពីការឆ្លើយតប ឬបានធ្វើ សម្រាប់ការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ ក៏ដូចជាការជួយដល់អ្នកទទួលផល។ សកម្មភាពចម្បងជាច្រើន ត្រូវបានធ្វើឡើងតាំងពីការលើកកំពស់ការយល់ដឹង តាមរយៈការប្រើប្រាស់សម្ភារអបរំផ្សព្វផ្សាយផ្សេងៗ ក៏ដូចជាព្យាយាមគ្រប់គ្រង និងគាំទ្រជាមួយនឹងការឆ្លើយតបបន្ទាន់សម្រាប់ការការពារដល់ភាគីពាក់ព័ន្ធ។ ការឆ្លើយតបទាំងនេះមានភាពសមស្របសម្រាប់អង្គការ ដែលមានគម្រោងកញ្ចប់ថវិកាសម្រាប់អនុវត្តនលើការងារផ្សេងៗ ខណៈដែលអង្គការដែលមិនមានថវិកាបែបនេះ ស្វែងរកកិច្ចសហការនិងជំនួយពីអង្គការដៃគូរបស់ខ្លួន និងព្យាយាមធ្វើការត្រួតពិនិត្យឡើងវិញពីកម្មវិធីក្នុងស្ថាប័នរបស់ខ្លួន និងវិភាជន៍ថវិកាដ៏សមស្រមសម្រាប់ការឆ្លើយតបពីជំងឺរាតត្បាតនេះ។

*តារាង៤.២. អ្វីដែលបានធ្វើក្នុងការឆ្លើយតប និងការផ្តល់ជំនួយដល់អ្នកទទួលផល*

| អ្វីដែលបានធ្វើសម្រាប់កម្មវិធីក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ១៩ | ប្រេកង់ |
|---|---|
| លើកកម្ពស់ការយល់ដឹង ការចែកចាយ និងសម្ភារប្រើប្រាស់ទប់ស្កាត់ផ្សេងៗ | ៤០ |
| រៀបចំការធ្វើការពីចម្ងាយ និងការណែនាំពីសុវត្ថិភាពសម្រាប់បុគ្គលិកនិងដៃគូ | ៣២ |
| ពន្យាពេលសកម្មភាពភាគច្រើន ឬក៏លុបចោលសកម្មភាពទាំងនោះ | ២២ |

| | |
|---|---|
| កាត់បន្ថយការជួបជុំ និងធ្វើតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល/ក្រសួងសុខាភិបាល | ១៦ |
| ផ្តល់នូវសម្ភារៈ និងចែកកញ្ចប់ជំនួយសង្គ្រោះ | ១១ |
| ផ្លាស់ប្តូរវិធីសាស្ត្រធ្វើការ ឧទាហរណ៍ តាមប្រព័ន្ធអនឡាញ និងរក្សាការឆ្លើយតបសម្រាប់ភាពចាំបាច់នៃសហគមន៍/អ្នកទទួលផល | ១០ |
| ពិនិត្យមើលផែនការ និងរៀបចំសកម្មភាពឆ្លើយតបនឹងជំងឺកូវីដ១៩ | ៦ |
| ធ្វើការជាមួយរដ្ឋាភិបាល និងចាត់វិធានការការពារ | ៦ |
| ទំនាក់ទំនងជាមួយនឹងអ្នកទទួលផលអំពីការផ្លាស់ប្តូរ | ៤ |
| ចែករំលែកថវិកាសម្រាប់ការឆ្លើយតប និងបន្តទំនាក់ទំនងជាមួយម្ចាស់ជំនួយ | ៤ |
| មិនបានធ្វើអ្វីជាដុំកំភួននោះទេ ដោយហេតុតែវាកើតឡើងភ្លាមៗ | ៣ |
| អាចធ្វើតាមផែនការ ដោយសារតំបន់គោលដៅនៅដាច់ស្រយាល និងតំបន់ព្រៃ | ២ |
| រៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រដោះស្រាយ | ២ |
| បន្តតាមដានពីការរីករាលដាល និងធ្វើតាមសេចក្តីណែនាំអំពីអនាម័យ | ២ |
| ពិនិត្យគម្រោងឡើងវិញ និងរៀបចំសកម្មភាពថ្មីៗមួយចំនួនដោយបន្តរក្សាគោលដៅ និងលទ្ធផល | ១ |

## ៤.៣. សកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន

### ៤.៣.១. បញ្ហាប្រឈមមុខនៃកម្រិតស្ថាប័ន

ក្នុងផ្នែកសំខាន់នេះបង្ហាញពីសកម្មភាព និងផលប៉ះពាល់កម្រិតស្ថាប័ន។ ជាលទ្ធផល តាមរយៈរូបខាងក្រោម បង្ហាញពីកម្រិតដែលអាចប្រៀបធៀបគ្នាសម្រាប់បញ្ហាប្រឈមជាមួយ កម្រិតគម្រោងនិងសកម្មភាព ដូចដែលបានរៀបរាប់ខាងលើ។ ជាទូទៅ តិចឬច្រើនស្ទើរតែរាល់អង្គការទាំងអស់បាននឹងប្រឈមបញ្ហា លើកលែងតែអង្គការចំនួន២តែប៉ុណ្ណោះ ដែលអាចធ្វើការតាមការគ្រោងទុកដោយគ្មានការបង្ហាញនូវបញ្ហាប្រឈម ក៏ប៉ុន្តែធ្វើការជាមួយភាពប្រុងប្រយ័ត្នផងដែរ។ ប្រសិនជាមើលពីកម្រិតនៃបញ្ហាប្រឈមវិញ មានចំនួន១៤% (២០ អង្គការ) ដែលស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ ដែលមិនអាចធ្វើសកម្មភាពទាំងអស់ដូចទៅនឹងការគ្រោងទុកនោះឡើយ។

*រូប ៤.៧. បញ្ហាប្រឈមបច្ចុប្បន្នសម្រាប់អង្គការ*




## ៤.៣.២. សកម្មភាពអង្គការ និងការពិចារណាយ៉ាងហ្មត់ចត់ ដើម្បីឆ្លើយតបជំងឺកូវីដ១៩

លទ្ធផលនេះចង្អុលបង្ហាញពីសកម្មភាព និងអ្វីកំពុងពិចារណាយ៉ាងល្អិតល្អន់ ដើម្បីរៀបចំសម្រាប់ការឆ្លើយតបជាលក្ខណៈស្ថាប័ន។ រាល់អ្នកឆ្លើយតបទាំងអស់ បានធ្វើរឿងមួយចំនួន និងពិចារណាយ៉ាងយកចិត្តទុកដាក់ ដើម្បីចាត់វិធានការប្រហាក់ប្រហែល ក្នុងចំណោមប្រភេទចម្លើយផ្សេងៗគ្នាដែលពាក់ព័ន្ធតាំងពីបុគ្គលិក ម្ចាស់ជំនួយ អ្នកទទួលផល និងភាគីពាក់ព័ន្ធផ្សេងៗ។ ក្នុងចំណោមចម្លើយទាំងនោះមាន ៩៤% បានលើកកម្ពស់សេវាសុខភាព និងការអនុវត្តសុវត្ថិភាពសម្រាប់បុគ្គលិក ហើយមាន ៨៨% បានបន្តការជូនដំណឹងទៅកាន់ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធអំពីការផ្លាស់ប្តូរគម្រោង ហើយ ៨៧% បានអនុញ្ញាតឱ្យបុគ្គលិករៀបចំអោយមានភាពបត់បែនសម្រាប់ការអនុវត្តការងារ (ឧទាហរណ៍ ធ្វើការពីផ្ទះ)។

ក្នុងការស្វែងរកដំណោះស្រាយ ឬសកម្មភាពផ្សេងៗ ក្រៅពីនេះ មានត្រឹមតែ ៤% ប៉ុណ្ណោះដែលមានអ្នកឆ្លើយតបផ្សេងៗគ្នាដូចជម្រាបជូនខាងក្រោម៖

- ស្នើសុំមូលនិធិសម្រាប់ការឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ១៩
- រៀបចំគោលនយោបាយបុគ្គលិក និងផែនការបន្តផ្សេងៗ ពាក់ព័ន្ធបុគ្គលិក
- ផ្តល់នូវមូលនិធិពិសេសដើម្បីជួយបុគ្គលិកនិងក្រុមគ្រួសារក្នុងករណីបិទបង្ខាំងការចេញចូល
- ពង្រីកវិសាលភាពនៃការរៀបចំផ្នែកវិជ្ជសាស្ត្រ
- ផ្តល់ជូននូវប្រាក់ខែមុនចំនួនមួយខែសម្រាប់បុគ្គលិក
- អនុញ្ញាតឱ្យបុគ្គលិកអាចយកសម្ភារចាំបាច់ពីការិយាល័យទៅធ្វើការនៅផ្ទះ

*រូប ៤.៨. សកម្មភាពដែលបានធ្វើ និងពិចារណាយ៉ាងហ្មត់ចត់ ដើម្បីចាត់វិធានការ*




## ៤.៣.៣.សកម្មភាពឆ្លើយតប ប្រសិនបើការឆ្លងនៅតែបន្តរហូតដល់រយៈពេលខែ ឬយូរជាងនេះ

គោលបំណងសំណួរនៅក្នុងផ្នែកនេះគឺការទទួលនូវចម្លើយបើក ដែលព្យាយាមដើម្បីទទួលបាននូវការធ្វើសកម្មភាពទាំងឡាយណា ដែលអាចកើតមានឡើងផ្សេងៗគ្នា ក៏ដូចជាទទួលបានគំនិតដើម្បីដោះស្រាយពីការរីកសាយភាយឆ្លងបន្តនៃជំងឺកូវីដ១៩ ប្រសិនបើវានឹងនៅតែបន្តក្នុងរយៈពេលរហូតដល់បីខែទៀត ឬកាន់តែអូសបន្លាយវែងជាងនេះ។

*តារាង ៤.៣. សកម្មភាពឆ្លើយតបកំឡុងពេលជំងឺកូវីដ១៩ ប្រសិនបើវានៅតែបន្តរីកសាយភាយនៅក្នុងរយៈពេលរហូតដល់៣ខែ ឬយូរជាងនេះ*

| លទ្ធភាពឆ្លើយតបក្នុងកំឡុងពេលជំងឺកូវីដ ១៩ | ប្រេកង់ |
|---|---|
| ការលើកឡើងទៅកាន់ម្ចាស់ជំនួយសម្រាប់ការពន្យាពេលសកម្មភាពមួយចំនួន និងពន្យាការចំណាយកញ្ចប់ថវិកា | ១៦ |
| បន្តធ្វើការពីផ្ទះ និងរៀបចំមធ្យោបាយទំនាក់ទំនងតាមប្រព័ន្ធអនឡាញ និងមធ្យោបាយសុវត្ថិភាពសម្រាប់ការងារ | ១៥ |
| មិនប្រាកដនៅឡើយ និងចាំមើល ហើយនឹងធ្វើការពិភាក្សាបន្ថែមទៀតជាមួយក្រុមគ្រប់គ្រងជាន់ខ្ពស់ និងអ្នកពាក់ព័ន្ធសំខាន់ៗ | ១៤ |

| | |
|---|---|
| រៀបចំវិធីសាស្ត្រធ្វើការងារថ្មី ដំណោះស្រាយជាយុទ្ធសាស្ត្រដោយកែសម្រួលអន្តរាគមន៍មួយចំនួន | ១៤ |
| លើកកម្ពស់ការយល់ដឹង សម្ភារផ្សព្វផ្សាយទៅកាន់សហគមន៍អ្នកទទួលផល | ១១ |
| ទំនាក់ទំនងជាមួយនឹងអ្នកទទួលផល/សហគមន៍ ហើយនិងស្វែងរកមធ្យោបាយដើម្បីជួយដល់ពួកគេ | ៧ |
| ព្យាយាមធ្វើការស្របតាមផែនការ និងកំណត់អាទិភាពការងារ ដោយអនុវត្តគោលការណ៍ណែនាំសុវត្ថិភាព | ៥ |
| គ្រប់គ្រងថវិកា សម្រាប់ភាពបន្ទាន់ និងជំនួយមនុស្សធម៌ ទៅកាន់អ្នកទទួលផល និងជនដែលងាយរងគ្រោះ | ៤ |
| ទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធ (ម្ចាស់ជំនួយ អាជ្ញាធរ សហគមន៍ និងដៃគូ) ហើយអាចមានភាពបត់បែនអាស្រ័យទៅលើស្ថានភាព | ៣ |
| កំណត់អ្វីដែលអាចបត់បែន ឬក៏ពន្យាបាន ហើយអនុវត្តតែការងារជាអាទិភាព | ៣ |
| ជួយបន្ថែមទៀតចំពោះសិស្សនិស្សិត លោកគ្រូ-អ្នកគ្រូ ឪពុកម្ដាយនៅក្នុងការបង្រៀនកូន និងការហ្វឹកហាត់កូន និងសម្ភារផ្សេងៗទៀត | ២ |
| គម្រោងនឹងត្រូវបានបញ្ចប់ និងមានគម្រោងមួយចំនួនទៀតគឺកំពុងព្យាយាមសម្រេច ឬក៏អាចនឹងឆាប់បិទបញ្ចប់ | ២ |
| ចូលរួមកិច្ចខិតខំប្រឹងប្រែងនៅក្នុងការគ្រប់គ្រងការរីកឆ្លងនៃជំងឺរាតត្បាត និងធ្វើតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល | ២ |
| ចូលរួមកិច្ចខិតខំប្រឹងប្រែងជាមួយនឹងអង្គការសង្គមស៊ីវិល ជាពិសេសជាកម្រិតថ្នាក់ក្រោមជាតិ ក៏ដូចជាគាំទ្រដល់អង្គការសង្គមស៊ីវិលនៅមូលដ្ឋាន | ១ |
| អាចជួយរាយការណ៍បញ្ជូនករណីឆ្លង ទៅកាន់មន្ទីរពេទ្យ និងទាក់ទងអាជ្ញាធរមូលដ្ឋានសម្រាប់ការជួយយ៉ាងសកម្មចំពោះអ្នកដែលឆ្លងជំងឺ | ១ |
| កាត់បន្ថយការអនុវត្តកម្មវិធីដល់ទៅ៥០% | ១ |
| កាត់បន្ថយការចំណាយតាមលទ្ធភាពដែលអាចធ្វើទៅបាន | ១ |
| គ្រប់បុគ្គលិកបន្តស្នាក់នៅផ្ទះ និងមួយភាគធំនៃប្រាក់ខែត្រូវបានកាត់បន្ថយ | ១ |
| សកម្មភាពកសិកម្មតាមរដូវកាលមួយចំនួនអាចចាំបាច់បន្តធ្វើឡើងវិញ ប្រសិនមិនមានការហាមប្រាម ឬរឹតបន្តឹងពីរដ្ឋាភិបាល | ១ |
| ស្វែងរកហិរញ្ញវត្ថុដើម្បីជួយក្រុមមនុស្សដែលរងផលប៉ះពាល់ | ១ |

**លទ្ធភាពឆ្លើយតបបន្ទាប់ពីជំងឺកូវីដ១៩ (មានការលើកឡើងផ្សេងៗគ្នា)**

- មានគណៈកម្មការសុវត្ថិភាពប្រចាំប្រទេស ដើម្បីជួបពិភាក្សាជាទៀងទាត់ និងពិភាក្សាបន្ថែម
- ត្រួតពិនិត្យឡើងវិញ/លុបចោលសកម្មភាពសំខាន់ៗមួយចំនួន និងបន្តសន្សំលើការចំណាយ
- កាត់បន្ថយបុគ្គលិក និងបន្តរក្សាការទាក់ទងជាមួយនឹងម្ចាស់ជំនួយ
- មានការលំបាកដើម្បីអនុវត្តនូវកម្មវិធីសម្មភាពមួយចំនួន ហើយនឹងចាំបាច់បង្កើតការរៀបចំដទៃទៀតជាមួយនឹងម្ចាស់ជំនួយ
- អាចវិលត្រឡប់មកធ្វើការដូចដើមវិញយោងទៅតាមគម្រោងសកម្មភាព និងរំពឹងថាម្ចាស់ជំនួយនិងយល់ពីបញ្ហាទាំងនេះ
- បានរៀបចំអ្វីដែលជាការឆ្លើយតបរួចរាល់ទៅនឹងផលប៉ះពាល់នេះសម្រាប់រយៈពេល៦ខែ
- បន្តធ្វើសកម្មភាពការពារ ដូចជាការផ្សព្វផ្សាយឱ្យមានការយល់ដឹងបន្ថែម ទំនាក់ទំនងបន្ទាន់ (នគរបាល សង្កាត់ មណ្ឌលសុខភាព) ផ្តល់នូវសម្ភារៈការពារដូចជា ម៉ាស់ អាកុល សាប៊ូលាងដៃ ជាដើម ហើយនិងកញ្ចប់ស្បៀងសង្គ្រោះ (អាហារស្ងួត និងកំប៉ុង)
- បន្តការទាក់ទងនិងតាមដានជាមួយអ្នកទទួលផល ដើម្បីផ្តល់ការលើកទឹកចិត្ត និងជំនួយចាំបាច់ តាមលទ្ធភាពដែលអាចធ្វើបាន
- រៀបចំសម្រាប់ការបណ្តុះបណ្តាលលើបញ្ហាតានតឹង និងបញ្ហាផ្លូវចិត្តផ្សេងៗ ទៅកាន់អ្នកទទួលផលដើម្បីដោះស្រាយក្រោយពេលនៃការរាតត្បាត
- ពង្រឹងផ្នែកចិត្តសាស្ត្ររបស់បុគ្គលិកល្អប្រសើរឡើងវិញ និងការងាយសម្របខ្លួន-ពិចារណាពីការប្រតិបត្តិការ ព្យួរការប្រកាសរើសបុគ្គលិកលើតួនាទីមួយចំនួនមិនសូវចាំបាច់
- គ្រោងជួយទ្រទ្រង់ និងស្តារជីវភាពរស់នៅអោយមានភាពប្រសើរឡើងវិញ រួមទាំងប្រាក់ចំណូល
- ជួយគាំទ្រអង្គការសង្គមស៊ីវិលមូលដ្ឋាន ដើម្បីពង្រឹង និងធ្វើឱ្យមានភាពល្អប្រសើរលើស្ថានភាពសង្គមសេដ្ឋកិច្ច
- ផ្តោតការយកចិត្តទុកដាក់បន្ថែមលើជំនួយឧបត្ថម្ភសម្រាប់ស្ថានភាពគ្រីក្រខ្លាំង
- ព្យាយាមសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានទៅតាមលទ្ធភាព ដែលអាចធ្វើបានដើម្បីសម្រេចគម្រោងសកម្មភាពនៅពេលស្ថានភាពល្អប្រសើរវិញ
- បង្កើនសកម្មភាពហ្វឹកហាត់ទ្វេដងនៅក្នុងសហគមន៍
- វិលត្រឡប់ទៅកាន់រាល់មេរៀនកំឡុងពេលនៃដើមវិស្សមកាលរបស់ពួកគេ ដើម្បីធ្វើឱ្យប្រាកដថា សិស្សទាំងអស់បានយល់ដឹងច្បាស់ពីមេរៀន

- ធ្វើសម្រង់ស្ទង់មតិបន្ទាប់ពីស្ថានភាពវិលត្រឡប់ល្អដូចដើមវិញ ដើម្បីមើលឱ្យឃើញថានរណាដែលត្រូវការជំនួយបន្ថែមទៀត ហើយនិងផ្តល់កញ្ចប់អាហារបន្ថែមក្នុងករណីចាំបាច់

### ៩.៣.៩. គណនេយ្យភាពសម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងអ្នកទទួលផល ប្រសិនបើបន្តការឆ្លង

នៅក្នុងផ្នែកនេះ គឺជាប្រភេទសំណួរបើក សម្រាប់រាល់ចម្លើយទាំងអស់ ដែលព្យាយាមដើម្បីទទួលបាននូវរាល់លទ្ធភាពផ្សេងៗ ក៏ដូចជាគំនិតទាំងឡាយណា សម្រាប់លើកឡើងមកដោះស្រាយបញ្ហាគណនេយ្យភាពសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា បុគ្គលិក ម្ចាស់ជំនួយ និងដៃគូមូលនិធិ ព្រមទាំងអ្នកទទួលផល ប្រសិនបើជំងឺកូវីដ១៩នេះ នៅតែបន្តកើតមានរីកឆ្លងក្នុងរយៈពេល៣ខែក្រោយទៀត ឬយូរជាងនេះ។ មានអ្នកឆ្លើយតបជាច្រើនមិនទាន់បានចែករំលែកការឆ្លើយតបរបស់ពួកគេនៅឡើយ ឬក៏មិនទាន់មានគំនិតនៅឡើយ ហើយត្រូវការការពិភាក្សាលម្អិតបន្ថែមជាមួយនឹងអ្នកសម្រេចចិត្តសំខាន់ៗ ឬក៏រង់ចាំមើល និងរៀនសូត្រពីលទ្ធផលនៅក្នុងសិក្សានេះ។ ទោះបីជាយ៉ាងណាក៏ដោយចំនួននៃអង្គការជាច្រើនបានចែកករំលែកលទ្ធភាពនៃដំណោះស្រាយ និងសកម្មភាពឆ្លើយតបទៅនឹងគណនេយ្យភាពទៅកាន់អ្នកដើរតួពាក់ព័ន្ធផ្សេងៗគ្នា ហើយមានភាពចម្រុះគ្នានៃគំនិត និងលទ្ធភាពដំណោះស្រាយ ដែលបានប្រមូលផ្តុំឡើង ហើយវិភាគច្របាច់បញ្ចូលគ្នាដូចចំណុចខាងក្រោមនេះ។

| **គណនេយ្យភាពបុគ្គលិក ប្រសិនបើការឆ្លងនៅតែបន្តនៅក្នុងរយៈពេល៣ខែក្រោយ** |
|---|
| - រៀងរាល់បុគ្គលិកដែលមិនមានការងារដែលទទួលខុសត្រូវសំខាន់ នឹងមានការចរចារដើម្បីផ្អាកកុងត្រាការងារ ដែលជាជម្រើសចុងក្រោយ។ ប៉ុន្តែបើសិនជាម្ចាស់ជំនួយនៅតែអាចទ្រាំទ្រលើប្រាក់ខែបុគ្គលិកបាន ឬក៏ចុងបញ្ចប់ត្រូវព្យួរការងារដោយមិនទទួលបានកម្រៃ |
| - ត្រៀមសម្រាប់ភាពបត់បែន ប្រសិនបើនៅតែបន្តការងារធ្វើពីផ្ទះ ឬក៏ប្រាក់ខែរបស់បុគ្គលិកត្រូវបានកាត់បន្ថយពីកញ្ចប់ថវិកាដែលមាន |
| - ពិភាក្សា និងពិនិត្យគម្រោងឡើងវិញ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រការងារថ្មី |
| - នៅតែបន្តបើកប្រាក់ខែជូនបុគ្គលិក ពីព្រោះពួកគេនៅតែកំពុងធ្វើការងារពីចម្ងាយ តែត្រូវមានគម្រោងផែនការការងារច្បាស់លាស់ ដើម្បីបញ្ជូនទៅកាន់ប្រធានគ្រប់គ្រងផ្ទាល់ |
| - ដរាបណាម្ចាស់ជំនួយមានបំណាងនឹងបន្តផ្តល់មូលនិធិជំនួយ យើងនឹងនៅតែអាចរៀបចំចាត់ចែងបើកប្រាក់ខែជូនបុគ្គលិកពេញ ១០០% |
| - បន្តរក្សាការធ្វើការពីចម្ងាយ និងការទំនាក់ទំនង ឬក៏កាត់បន្ថយ ចំនួន៥០% ឬតិចជាងនេះ នៃប្រាក់ខែ និងអត្ថប្រយោជន៍របស់បុគ្គលិក |

- បុគ្គលិកទាំងអស់អាចឈប់សម្រាកដោយមិនទទួលបានប្រាក់ខែ លើកលែងតែបុគ្គលសំខាន់ៗ
- ការកាត់បន្ថយចំនួនបុគ្គលិក ដោយអនុលោមទៅតាមច្បាប់ការងារ
- បុគ្គលិកអាចចាកចេញ ដោយគ្មានការបង់ជូន និងអាចបន្តរក្សាការងារតាមប្រព័ន្ធអនឡាញ
- គ្រប់គ្រងការងារក្រៅម៉ោងសម្រាប់បុគ្គលិក
- បើសិនជាមិនមានការជួយគាំទ្រពីម្ចាស់ជំនួយទេ រក្សាតែបុគ្គលិកណាសំខាន់ និងផ្នែកប្រតិបត្តិការដែលចាំបាច់

## គណនេយ្យភាពម្ចាស់ជំនួយ បើសិនការឆ្លងនៅតែបន្តមានក្នុងរយៈពេល៣ខែក្រោយ

- ពិគ្រោះយោបល់ជាមួយនឹងដៃគូហិរញ្ញវត្ថុ ពិនិត្យសកម្មភាពគម្រោងឡើងវិញ ដែលអាចអនុវត្ត និងសម្របទៅនឹងផលប៉ះពាល់ពីស្ថានភាពជំងឺកូវីដ១៩
- លើកឡើងទៅកាន់ម្ចាស់ជំនួយ និងដៃគូហិរញ្ញវត្ថុសម្រាប់ពន្យាពេល និងជួយគាំទ្រលើប្រាក់ខែបុគ្គលិក
- ស្នើសុំទៅកាន់ម្ចាស់ជំនួយសម្រាប់ការពន្យាផែនការ អត្ថប្រយោជន៍បុគ្គលិកនឹងត្រូវយកមកពិចារណាដើម្បីប្រើប្រាស់យុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាគរយមួយចំនួន និងស្នើសុំបន្តគាំទ្រខ្លះៗពីម្ចាស់ជំនួយ
- បន្តធ្វើបច្ចុប្បន្នភាពឱ្យម្ចាស់ជំនួយបានដឹងអំពីស្ថានភាព ហើយពួកគេនឹងយល់ដូចអ្វីបានកើតឡើងដោយហេតុតែមានផលប៉ះពាល់គ្រប់ប្រទេស
- ចរចារជាមួយនឹងម្ចាស់ជំនួយដើម្បីបន្តរក្សាចំនួនបុគ្គលិក ពីព្រោះនេះគឺជាបញ្ហាសាកល
- អនុវត្តការសន្សំចំណាយ និងបង្អាករាល់ការចំណាយទៅលើបេសកកម្មណាដែលមិនមែនជាកិច្ចការស្នូល
- ស្នើសុំសម្រាប់ពេលវេលានូវរាល់ការអនុវត្តគម្រោង
- ការផ្អាកជាបណ្តោះអាសន្ននូវតួនាទីមួយចំនួន និងបង្ហាញពីគណនេយ្យសន្សំ សម្រាប់បុគ្គលិកដែលគួរតែមានជម្រើស
- នឹងស្នើសុំម្ចាស់ជំនួយសម្រាប់បន្តរយៈពេលការងារ ហើយប្រាក់ខែនៅតែបើកជូនរាល់គ្រប់បុគ្គលិកទាំងអស់

- នៅតែចាំបាច់ទទួលការជួយពីម្ចាស់ជំនួយសម្រាប់ប្រាក់ខែបុគ្គលិកដោយពួកគេ នៅតែបន្តធ្វើការពីផ្ទះ
- មូលនិធិជំនួយភាគច្រើននឹងត្រូវបានបដិសេធប្រើប្រាស់ពីព្រោះម្ចាស់ជំនួយក៏កំពុងប្រឈមនឹងបញ្ហានេះដែរ
- រៀបចំរាល់ធនធាន ហើយជូនដំណឹងទៅម្ចាស់ជំនួយនូវអ្វីដែលពួកយើងកំពុងប្រឈម
- លើកឡើងទៅម្ចាស់ជំនួយនិងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពន្យាពេលការអនុវត្ត ស្នើសុំការបន្ថយពេលវេលាបន្ថែមបើសិនវាជាករណីចាំបាច់ ឬក៏មានការប្រែប្រួលសកម្មភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការភ្លាមៗបណ្តាលមកពីវិបត្តិនេះ

## គណនេយ្យភាពអ្នកទទួលផល បើសិនបើការឆ្លងនៅតែបន្តក្នុងរយៈ៣ខែក្រោយ

- នៅតែបន្តជួយផ្តល់នូវតម្រូវការចាំបាច់រហូតទាល់តែពួកយើងមិនអាចទៅខាងក្រៅដើម្បីផ្តល់សេវាកម្មបាន និងបន្ទាប់មកពួកយើងនឹងជូនដំណឹងប្រសិនបើបញ្ឈប់កម្មវិធី
- សម្លឹងមើលពីជម្រើសធ្វើការផ្សេងទៀត ដើម្បីអាចបន្តនូវប្រតិបត្តិការ និងហិរញ្ញវត្ថុ
- មិនទាន់ច្បាស់លាស់នៅឡើយត្រង់ចំនុចនេះ វាជាការល្អដែលបានលឺពីរដ្ឋាភិបាល និងម្ចាស់ជំនួយសំខាន់ៗនូវអ្វីដែលពួកគេណែនាំដល់ពួកយើង
- ពន្យាពេលជាបណ្តោះអាសន្ន ធ្វើការជាមួយអ្នកទទួលផល
- រៀបចំបុគ្គលិក ធ្វើការងារបែបគំរូឆ្លាតវៃតាមលទ្ធភាពដែលអាចធ្វើបាន ហើយនឹងកែប្រែសកម្មភាពដែលអាចធ្វើបានមួយចំនួនដូចជា ការប្រជុំ សិក្ខាសិលា តាមប្រព័ន្ធអនឡាញជាមួយនឹងអ្នកពាក់ព័ន្ធ និងអ្នកទទួលផល

## ៥. សំណូមពរ និងយោបល់ផ្សេងៗ

យោបល់ និងសំណូមពរផ្សេងៗ ត្រូវបានច្របាច់បញ្ចូលដូចមានខាងក្រោមនេះ ដែលបានលើកឡើងសម្រាប់ភាគីពាក់ព័ន្ធសំខាន់ៗ។

### ៥.១. សម្រាប់ អង្គការ ត.ស.ក

| សម្រាប់អង្គការ ត.ស.ក | ប្រេកង់ |
|---|---|
| **ចែករំលែកព័ត៌មាន** | |
| ចែករំលែកព័ត៌មានទៀងទាត់ និងផ្តល់ដំបូន្មានទាន់ពេលវេលា (ផ្នែកច្បាប់ ស្ថានភាពជំងឺកូវីដ១៩ និងពីផលប៉ះពាល់របស់វាជាដើម) តាមរយៈវេទិកាតាមប្រព័ន្ធអនឡាញ | ៥០ |
| ចែករំលែកព័ត៌មានពីការប្រឈម បញ្ហានិងក្តីព្រួយបារម្ភរបស់អង្គការសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាល ទៅកាន់រដ្ឋាភិបាល ជាពិសេសនោះគឺម្ចាស់ជំនួយ (ប្រាក់ខែ និងអត្ថប្រយោជន៍បុគ្គលិក កំឡុងពេលនៃស្ថានភាពនេះ ការកែសម្រួលថវិកាឡើងវិញ។ល។) | ១៧ |
| ផ្តល់ការជួយគាំទ្រ និងចែករំលែកព័ត៌មានទៅកាន់បណ្តាញអង្គការមិនមែនរដ្ឋាភិបាលតាមបណ្តាខេត្ត និងអង្គការសហគមន៍មូលដ្ឋានពីកូវីដ១៩ អោយទាន់ពេលវេលា | ៦ |
| ធ្វើការសម្របសម្រួល ដើម្បីចែករំលែកព័ត៌មានពីសមាជិក និងបន្តធ្វើបច្ចុប្បន្នភាពអំពីជំងឺកូវីដ១៩ | ១ |
| **គៀរគរធនធាន និងការជួយគាំទ្រ** | |
| គៀរគរធនធានដើម្បីជួយគាំទ្រ ក្រុមគោលដៅ និងសហគមន៍ ដែលស្ថិតនៅក្នុងស្ថានភាពនៃជំងឺកូវីដ១៩ (តាមរយៈគាំទ្រផ្តល់មូលនិធិទៅកាន់សមាជិកអង្គការមិនមែនរដ្ឋាភិបាល) | ២២ |
| ផ្តល់នូវ ឧបករណ៍ដែលអាចដាក់ដំណើរការបាន ដើម្បីជំនួយកម្មវិធីរៀនសូត្រសម្រាប់អង្គការមិនមែនរដ្ឋាភិបាលតូចៗ ដែលត្រូវការចាំបាច់ (ទូរស័ព្ទទាក់ទងកុំព្យូទ័រយួរដៃ ដែលអាចបន្តជួយការងារ និងគម្រោងរបស់ពួកគេ) | ១ |
| ធ្វើការសម្របសម្រួលគាំទ្រពីសមាជិក ដើម្បីដោះស្រាយបញ្ហាផ្សេងៗ | ១ |
| **ជំនួយជាសម្ភារៈអនាម័យ និងសម្ភារអប់រំផ្សេងៗ** | |
| ចែករំលែកសារសម្រាប់ការការពារ និងសម្ភារផ្សព្វផ្សាយដូចជា ផ្ទាំងរូបភាព ខិតប័ណ្ណ ឯកសារផ្សេងៗ។ល។ | ១៣ |

| | |
|---|---|
| ✚ ការចែកចាយនូវសម្ភារៈអនាម័យ (ម៉ាស់ ដែល អាកុល ឧបករណ៍វាស់កំដៅជាដើម) | ៨ |
| **ការរៀនសូត្រ និងអភិវឌ្ឍន៍សមត្ថភាព** | |
| ✚ រៀបចំព្រឹត្តិការណ៍កសាងសមត្ថភាព និងវេទិកាតាមប្រព័ន្ធអនឡាញ | ៧ |
| ✚ ចែករំលែកលទ្ធផលពីការធ្វើសម្រង់មតិមកវិញ ( ផលប៉ះពាល់ពីជំងឺកូវីដ១៩ ទៅលើការងារអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា) | ៧ |
| ✚ អំពាវនាវសម្រាប់ការប្រជុំជាមួយនឹងដៃគូសម្រាប់ការពិភាក្សា និងរៀនសូត្រ ដើម្បីស្វែងរកនូវដំណោះស្រាយប្រសើរ ជាពិសេសនោះសម្រាប់បុគ្គលិកនិងអ្នកទទួលផល | ៦ |
| ✚ ផ្តល់ជូននូវការហ្វឹកហាត់ ការបង្រៀន និងឧបករណ៍រៀនសូត្រតាមរយៈប្រព័ន្ធអនឡាញ ទៅកាន់សាលារដ្ឋ ដើម្បីបន្តការរៀនសូត្ររបស់សិស្សក្នុងកំឡុងពេលជំងឺកូវិដ១៩ | ១ |
| ✚ ការសម្របសម្រួលតាមវិស័យផ្សេងៗ ដើម្បីទាញចេញនូវសកម្មភាពផ្សេង ឬថាតើគួរឆ្លើយតបរបៀបណា | ១ |
| **ផ្នែកច្បាប់ ការជួយគាំទ្រ និងពន្ធ** | |
| ✚ ចែករំលែកព័ត៌មានទៀងទាត់ និងផ្តល់ដំបូន្មានទៅលើវស័យផ្នែកច្បាប់ | ៣០ |
| ✚ គួរតែពិភាក្សាជាមួយនឹងរដ្ឋាភិបាល ដើម្បីគិតគូសម្រាប់និន្នាការពេលអនាគត បើសិនជាករណីនេះអាចកើតឡើងម្តងទៀត ហើយស្នើសុំមូលនិធិមួយចំនួន ដើម្បីរួមក្នុងការអនុវត្តការដល់អង្គកាសង្គមស៊ីវិល | ៥ |
| ✚ ការលើកលែងពន្ធគួរតែស្នើសុំទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥ |
| ✚ ជំនួយផ្សេងៗផ្នែកច្បាប់ | ៣ |
| **ការសិក្សាស្រាវជ្រាវ និងការវាយតម្លៃ** | |
| ✚ វាយតម្លៃលើផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅកាន់រដ្ឋាភិបាល និងម្ចាស់ជំនួយ | ៤ |
| ✚ គួរតែសិក្សា និងវិភាគលើច្បាប់ថ្មីក្នុងការគ្រប់គ្រងពេលដាក់ប្រទេសជាតិក្នុងភាពអាសន្ន ដែលទាក់ទងទៅនឹងបរិបទនៃច្បាប់ ហើយនឹងពីរបៀបដែលអាចធ្វើការតស៊ូមតិ | ២ |
| ✚ បង្កើតចេញជាករណីសិក្សានៃផលប៉ះពាល់ជំងឺកូវីដ១៩ចំពោះសហាគមន៍ និងសង្គម | ១ |

| | |
|---|---|
| **យន្តការការងារសម្រាប់អង្គការ សហគមន៍ និងអ្នកទទួលផល ព្រមទាំងអ្នកពាក់ព័ន្ធកំឡុងពេល និង បន្ទាប់ពីជំងឺកូវីដ១៩** | |
| ✚ គួរតែលើកឡើងពីវិធីសាស្ត្រនៃមធ្យោបាយទំនាក់ទំនង និងគ្រប់គ្រង នៃការធ្វើការពីចម្ងាយ | ៣ |
| ✚ បន្តនូវការប្រមូលផ្តុំនូវសំឡេងសង្គមស៊ីវិល និងបន្តគាំទ្រដល់រដ្ឋាភិបាលដែលជាដៃគូអភិវឌ្ឍន៍ | ៣ |
| ✚ បង្កើតគណៈកម្មការ នៃជំងឺកូវីដ១៩ សម្រាប់ការពិគ្រោះយោបល់ | ២ |
| ✚ យន្តការ ជួយទៅកាន់សហគមន៍ និងសង្គមបន្ទាប់ពីជំងឺកូវីដ១៩ | ២ |
| ✚ ពិចារណាពីសេចក្តីណែនាំ ឬជំនួយផ្នែកច្បាប់ទៅកាន់សមាជិកភាពអង្គការមិនមែនរដ្ឋាភិបាលអំពីការគ្រប់គ្រងបុគ្គលិកកំឡុងពេលការរីកសាយភាយឆ្លងជំងឺកូវីដ១៩ ខណៈដែលបុគ្គលិកមិនចុះធ្វើការងារបានឬមិនមានបន្ទុកការងារ និងការពិចារណាសម្រាប់ការគាំទ្រប្រាក់ខែ | ២ |
| ✚ គួរតែមានលិខិតរួមគ្នា ដើម្បីបើកបង្ហាញ/អំពាវនាវទៅកាន់ម្ចាស់ជំនួយ ដើម្បីកុំទាន់បញ្ចប់កុងត្រា/សកម្មភាព ដែលអាចផ្តល់ផលអាក្រក់ខ្លាំងដល់ការចំណាយលើបុគ្គលិក | ១ |
| ✚ បើសិនជា ការរីកសាយភាយឆ្លងនៅតែបន្តក្នុងរយៈពេល៣ខែ ឬវែងជាងនេះ និង ពិចារណាពីគណនេយ្យភាពចំពោះបុគ្គលិក ស្ថាប័ន និងម្ចាស់ជំនួយ | ៤ |
| **ការភ្ជាប់បណ្តាញ និងការសហការគ្នា** | |
| ✚ កសាងបណ្តាញជាមួយនឹងអង្គការសុខភាពពិភពលោក ភ្នាក់ងារកម្មវិធីជំនួយអភិវឌ្ឍរបស់សហរដ្ឋអាមេរិក អង្គការសហប្រជាជាតិសម្រាប់ទ្រទ្រង់កុមារ និងមជ្ឈមណ្ឌលសម្រាប់គ្រប់គ្រងនិងការពារជំងឺឆ្លង ដើម្បីបញ្ឈប់ការឆ្លង | ១ |
| **ផ្សេងៗទៀត** | |
| ✚ ការលើកលែងបង់ប្រាក់ចូលជាសមាជិកភាពរបស់អង្គការ គ.ស.ក នៅក្នុងឆ្នាំ ២០២០ | ១ |
| ✚ មិនមានចម្លើយ | ២៣ |

## ៥.២. សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ

| សម្រាប់ម្ចាស់ជំនួយ និងដៃគូផ្តល់មូលនិធិ | ប្រេកង់ |
|---|---|
| អនុញ្ញាតដល់ការពន្យាពេលអនុវត្តគម្រោង និងការកែសម្រួលអន្តរាគមន៍ | ៦២ |
| ការពិគ្រោះយោបល់ជាមួយនឹងម្ចាស់ជំនួយ ដើម្បីស្វែងរកជម្រើស/ដំណោះស្រាយលើរបៀបអនុវត្តគម្រោង និងជំនួយទៅកាន់ក្រុមគោលដៅកំឡុងពេលជំងឺកូវីដ១៩ | ៤២ |
| បង្កើនជំនួយមូលនិធិ ដើម្បីគាំទ្រប្រតិបត្តិការ និងសហគមន៍ ជាពិសេសនោះគឺតំបន់ដាច់ស្រយាល | ៤១ |
| អនុញ្ញាតសម្រាប់ប្រាក់ខែបុគ្គលិក និងអត្ថប្រយោជន៍ពេញលេញកំឡុងពេលជំងឺកូវីដ១៩ | ១៩ |
| ផ្តល់នូវជំនួយមូលនិធិលើសង្គ្រោះបន្ទាន់ អនាម័យ និងសម្ភារអនាម័យដូចជា ម៉ាស់ អាល់កុល ដែល សាប៊ូដុំ និងឧបករណ៍វាស់កម្តៅ ។ល។ | ១៧ |
| បន្តការចែករំលែកព័ត៌មាន ទំនាក់ទំនងយ៉ាងកក់ក្តៅតាមប្រព័ន្ធអនឡាញ និងការសម្រេចចិត្តនៅក្រោមស្ថានភាពនៃជំងឺកូវីដ១៩ | ៩ |
| គួរតែមានគោលនយោបាយច្បាស់លាស់សម្រាប់គាំទ្រជំនួយមូលនិធិ ក្នុងកំឡុងពេល និងក្រោយពេលជំងឺកូវីដ១៩ | ៨ |
| រៀបចំគម្រោងសម្រាប់ដំណាក់កាលក្រោយជំងឺកូវីដ១៩ | ២ |
| របៀបបង្កើតកម្មវិធីធ្វើការពីចម្ងាយ និងរបៀបឱ្យមនុស្សត្រឡប់មកធ្វើការធម្មតាវិញប្រកបដោយប្រសិទ្ធភាព | ១ |
| ផ្តល់នូវការរៀបចំកម្មវិធីដែលមានភាពបត់បែន ឬពង្រឹងអំណាចដល់អ្នកប្រើប្រាស់មូលនិធិ សម្រាប់ការកែច្នៃកម្មវិធីដែលអាចសម្របទៅនឹងស្ថានការណ៍ ដរាបណាវាឆ្លើយតបទៅនឹងគោលដៅ និងវត្ថុបំណងនៃរបៀបវារៈសម្រាប់ការអភិវឌ្ឍ និងអ្នកផ្តល់មូលនិធិ | ១ |
| រៀបចំសម្រាប់ការផ្លាស់ប្តូរសកម្មភាព គម្រោងដើម្បីផ្តល់ជំនួយសម្រាប់អ្នកដែលទទួលរងផលប៉ះពាល់ | ១ |
| មិនមានចម្លើយ | ១៤ |

## ៥.៣. សម្រាប់រាជរដ្ឋាភិបាល

| សម្រាប់រដ្ឋាភិបាល | ប្រេកង់ |
|---|---|
| ផ្តល់នូវសកម្មភាពសមរម្យ ដើម្បីបន្តរក្សាប្រទេសឱ្យមានសុវត្ថិភាព និងគោលការណ៍ណែនាំច្បាស់លាស់ | ៣០ |
| ផ្តល់នូវជំនួយអាហារទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ ជាពិសេសនោះពលរដ្ឋស្ថិតក្នុងតំបន់ដាច់ស្រយាល | ២៩ |
| បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ | ២៦ |
| ធ្វើបច្ចុប្បន្នភាព និងចែករំលែកព័ត៌មានដោយតម្លាភាព និងជឿទុកចិត្តអំពីជំងឺកូវីដ១៩ ហើយនិងផលប៉ះពាល់របស់វានៅក្នុងប្រទេសកម្ពុជា | ២៣ |
| ផ្តល់នូវមូលនិធិជំនួយទៅកាន់អង្គការមិនមែនរដ្ឋាភិបាល | ១៨ |
| អគ្គនាយកដ្ឋានពន្ធដារគួរតែលើកលែងការយកពន្ធលើប្រាក់ខែ និងពន្ធកាត់ទុក | ១៦ |
| ការចែកចាយនៃការការពារ សម្ភារ:អនាម័យ ទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ | ១៤ |
| សកម្មភាពចាំបាច់បន្ទាន់ លើការជួយលើកកម្ពស់ផ្នែកសេដ្ឋកិច្ច ខណ:ពេលដែលមានចំនួនអ្នកជួបការលំបាកកើនឡើងច្រើន បណ្តាលមកពីបាត់បង់ការងារ | ១៣ |
| រៀបចំគោលលនយោបាយសម្រាប់កាត់បន្ថយហានិភ័យ សម្រាប់បុគ្គលិកមិនមែនរដ្ឋ និងផែនការគាំទ្រផ្សេងៗ ខណ:ពេលដែលប្រទេសមួយចំនួនកំពុងតែធ្វើ | ១០ |
| បង្កើនការចែករំលែក និងយល់ដឹងពីជំងឺកូវីដ១៩ ហើយនិងការការពារ ជាពិសេសនោះតំបន់ជនបទ | ១២ |
| បង្កើនការធ្វើតេស្តជំងឺកូវីដ១៩ នូវរាល់អ្នកដែលជាប់សង្ស័យទាំងអស់ (ក្នុងទ្រង់ទ្រាយធំ) | ៧ |
| រក្សាតម្លៃសមរម្យលើទីផ្សារនៃការការពារ និងសម្ភារអនាម័យដូចជា ម៉ាស់ អាកុល ដែល និងឧបករណ៍វាស់កម្តៅ ។ល។ | ៦ |

| | | |
|---|---|---|
| ✚ | កាត់បន្ថយតម្លៃបង់ភ្លើងអគ្គិសនី និងតម្លៃផ្គត់ផ្គង់ប្រព័ន្ធទឹក | ៤ |
| ✚ | បើកសិទ្ធិសេរីភាពដល់ប្រជាជនក្នុងការបញ្ចេញមតិ លើជំងឺកូវីដ១៩ | ៤ |
| ✚ | ពន្យាពេលនៃការបង់ប្រាក់កម្ចី ទៅកាន់ មីក្រូហិរញ្ញវត្ថុ /ធនាគារ | ៣ |
| ✚ | ពន្យាពេលនៃការបង់ប្រាក់ទៅកាន់ មូលនិធិជាតិរបបសន្តិសុខសង្គម | ៣ |
| ✚ | ជំនួយសម្ភារការពារគ្រប់គ្រាន់ និងឧបករណ៍ពេទ្យទៅកាន់មន្ទីរពេទ្យ និងបុគ្គលិក | ៣ |
| ✚ | មិនអនុញ្ញាតឱ្យជនបរទេសចូលមកក្នុងប្រទេសកម្ពុជា | ២ |
| ✚ | ផ្តល់នូវការព្យាបាលដ៏ប្រសើរចំពោះប្រជាជនដែលមានភាពវិជ្ជមាននៃជំងឺកូវីដ១៩ | ២ |
| ✚ | ផ្តល់នូវការជួយពិសេសទៅកាន់មីក្រូ សហគ្រាស ដែលស្ថិតក្នុងកំឡុងពេលនេះ ដើម្បីឆ្លើយតបទៅនឹងការបង់ប្រាក់កម្ចី និងប្រតិបត្តិការ | ២ |
| ✚ | បង្កើតនូវសេចក្តីរាយការណ៍ប្រព័ន្ធអនឡាញទៅកាន់ មូលនិធិជាតិរបបសន្តិសុខសង្គម អគ្គនាយកដ្ឋានពន្ធដារ ។ល។ | ១ |
| ✚ | ចត្តាឡីស័កខ្លួនឯង គួរតែមានរយៈពេលយូរជាងនេះ ដោយមានការតាមដាន និងឧបត្ថម្ភផ្សេងៗ | ១ |
| ✚ | មិនមានចម្លើយ | ១៧ |

## ឧបសម្ព័ន្ធ១: គម្រូងសំណួរសម្រាប់ស្ទង់មតិ

| ID: | | | |
|---|---|---|---|

*(សម្រាប់អង្គការ គ.ស.ក)*

### បញ្ជីសំណួរ

### ការស្ទង់មតិរបស់សង្គមស៊ីវិល សម្រាប់សកម្មភាព និងផលប៉ះពាល់ពីជំងឺកូវីដ ១៩

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក.) ធ្វើការស្ទង់មតិនេះជាមួយអង្គការសមាជិក បណ្តាញអង្គការខេត្ត អង្គការសហគមន៍មូលដ្ឋាន និងដៃគូផ្សេងៗ ដែលធ្វើការជាមួយគម្រោងអង្គការសង្គមស៊ីវិល ដើម្បីស្វែងយល់សកម្មភាពនៃការឆ្លើយតប និងផលប៉ះពាល់ពាក់ព័ន្ធកម្មវិធី ស្ថាប័ន ក៏ដូចជាក្រុមគោលដៅផ្សេងៗ។

*សូមចំណាយពេលប្រមាណ១០នាទីសម្រាប់ការឆ្លើយតប ហើយព័ត៌មានទាំងនេះនឹងត្រូវប្រើសម្រាប់ការវិភាគទិន្នន័យរួម។*

*អរគុណជាមុនសម្រាប់ការចូលរួម។*

| **1. ព័ត៌មានទូទៅ** | |
|---|---|
| 1.1. ឈ្មោះអង្គការ | …………………………………………………………… |
| 1.2.ប្រភេទអង្គការ | a. អង្គការសហគមន៍មូលដ្ឋាន<br>b. អង្គការក្នុងស្រុក<br>c. អង្គការបរទេស<br>d. ផ្សេងៗ *(សូមបញ្ជាក់)*…… |
| 1.3.វិស័យការងារចំបងក្នុងអង្គការ (អប់រំ សុខភាព…) | …………………………………………………………… |
| 1.4.តួនាទីរបស់អ្នកផ្តល់ចម្លើយ | a. ថ្នាក់ដឹកនាំ/ថ្នាក់គ្រប់គ្រងជាន់ខ្ពស់<br>b. មន្ត្រីកម្មវិធី<br>c. មន្ត្រីប្រតិបត្តិ<br>d. ផ្សេងៗ*(សូមបញ្ជាក់)*…… |
| 1.5.ប្រភេទក្រុមគោលដៅធ្វើការជាមួយ *(ចម្លើយលើសពីមួយ)* | a. កុមារ<br>b. យុវជន<br>c. មនុស្សចាស់<br>d. ជនពិការ<br>e. ពលរដ្ឋទូទៅ<br>f. ផ្សេងៗ*(សូមបញ្ជាក់)*…… |
| 1.6.ខេត្ត/រាជធានីសម្រាប់កម្មវិធី | a. ភ្នំពេញ<br>b. ខេត្ត *(សូមបញ្ជាក់ទាំងអស់)*… |

| 2. សកម្មភាព និងផលប៉ះពាល់លើផែនការ និងសកម្មភាពការងាររបស់អ្នក | |
|---|---|
| 2.1. តើជំងឺកូវីដ១៩ ធ្វើអោយប៉ះពាល់ជាអវិជ្ជមានកម្រិតណាដល់ផែនការអនុវត្តការងាររបស់អ្នក? | a. មិនមានផលប៉ះពាល់ទេ<br>b. ប៉ះពាល់តិចតួច<br>c. ប៉ះពាល់មធ្យម<br>d. ប៉ះពាល់បង្គួរ<br>e. ប៉ះពាល់ខ្លាំង |
| 2.2. តើអ្នកបានធ្វើអ្វីខ្លះ ក្នុងការឆ្លើយតបទៅនឹងបញ្ហានេះ ក៏ដូចជាជួយដល់ក្រុមគោលដៅរបស់អ្នក? | ……………………………………………………………………<br>……………… |
| 2.3. តើមានផលលំបាក/បញ្ហាប្រឈមអ្វីខ្លះដែលបានជួប្រទះក្នុការអនុវត្តការងាររបស់អ្នក? | ……………………………………………………………………<br>…………… |

| 3. សកម្មភាព និងផលប៉ះពាល់សម្រាប់កម្រិតស្ថាប័ន | |
|---|---|
| 3.1. តើបញ្ហាប្រឈមដែលស្ថាប័នអ្នកកំពុងជួបប្រទះមានវិសាលភាពកម្រិតណា? | a. មិនមានបញ្ហាប្រឈម និងអាចធ្វើតាមផែនការ<br>b. មិនអាចបំពេញការងារមួយចំនួនតាមផែនការ<br>c. មិនអាចបំពេញការងារមួយចំនួនមធ្យមតាមផែនការ<br>d. មិនអាចបំពេញការងារមួយចំនួនធំតាមផែនការ<br>e. មិនអាចបំពេញសកម្មភាពទាំងអស់តាមផែនការ |
| 3.2. តើមានវិធានការអ្វីខ្លះដែលអ្នកបានលើកឡើង ឬគិតគូរត្រៀមឆ្លើយតប ជំងឺកូវីដ១៩? *(ចម្លើយលើសពីមួយ)* | a. លើកកម្ពស់សុខភាព និងសុវត្ថិភាពសម្រាប់បុគ្គលិក<br>b. ផ្តល់អោយបុគ្គលិកបត់បែនរបៀបធ្វើការ *(ធ្វើតាមផ្ទះ)*<br>c. បង្កើតយន្តការទំនាក់ទំនងដល់បុគ្គលិក និងអ្នកទទួលផល<br>d. រក្សាទំនាក់ទំនងជាមួយម្ចាស់ជំនួយអំពីការផ្លូផែនការ<br>e. សំណើដល់ម្ចាស់ជំនួយ និងដៃគូជំនួយសម្រាប់ការពន្យាពេល ចំណាយ<br>f. ផ្សេងៗ*(សូមបញ្ជាក់រាល់ចម្លើយផ្សេងៗ)*៖ ____ |
| 3.3. ប្រសិនបើជំងឺ កូវីដ១៩ នៅតែបន្តលើសពី៣ ខែ ឬយូរជាងនេះ តើអង្គការអ្នកនឹងឆ្លើយតបយ៉ាងណាក្នុងអំឡុងពេល និងក្រោយពេលមានបញ្ហា? | ……………………………………………………………………<br>……………………………………………………………………<br>……… |
| 3.4.ប្រសិនបើជំងឺនៅតែបន្តផ្ទុះ រហូតដល់បីខែឬយូរជាងនេះ តើអង្គការអ្នកនឹងគិតគូយ៉ាងណាពីគណនេយ្យភាព សម្រាប់បុគ្គលិក ម្ចាស់ជំនួយ និងសហគមន៍ *(ដូចជា ប្រាក់ខែ និង អត្ថប្រយោជន៍ របៀបធ្វើការជាដើម……)?* | ……………………………………………………………………<br>……………………………………………………………………<br>……………… |

| ៤. យោបល់ និងសំណូមពរផ្សេងៗ |
|---|
| 4.1. សម្រាប់អង្គការ គ ស គ……………………………………………………………………………………………………………………………<br>…………………………………………………………………………………………………………………………………………<br>…… |
| 4.2. សម្រាប់ដៃគូម្ចាស់ជំនួយ …………………………………………………………………………………………………………………<br>………………………………………………………………………………………… |
| 4.3. សម្រាប់រដ្ឋាភិបាល…………………………………………………………………………………………………………………………<br>…………………………………………………………………………………………………… |

**សូមអរគុណ!**

Accountability

GPP

05/10/2018 04/10/2021

Symbol of Trust

Cooperation Committee for Cambodia

Comité de Coopération Pour le Cambodge

CCC's 30th Anniversary in Sustainable Development in Cambodia

# គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)


ផ្ទះលេខ ៩-១១, ផ្លូវលេខ ៤៧៦, សង្កាត់ទួលទំពូង ១,
ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៨៨៥
រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

ទូរស័ព្ទលេខ: +855 (0)23 214 152 ទូរសារ: +855 (0)23 216 009

www.ccc-cambodia.org
info@ccc-cambodia.org
fb.com/CCCsince1990